# ការសំភាសន៍របស់ អ្នកមីង ចឹម យេន

កៈ អ្នកធ្វើការសំភាសន៍ គីម ម៉េង ខៈ អ្នកដែលត្រូវបានគេសំភាសន៍ ចឹម យេន

## <u>ការសង្ខេបរបស់អ្នកមីង ចឹម យេន</u>

អ្នកមីង ចឹម យេន គាត់មានអាយុ ៥៩ឆ្នាំ ក្នុងឆ្នាំ ២០១៨។អ្នកមីង ចឹម យេន ភេទស្រី។អ្នកមីង ចឹម យេន មានកូនចំនួន ៩ នាក់។អ្នកមីង ចឹម យេន ភូមិ ឧញ្ញ៉ាតី កោះ ឧញ្ញ៉ាតី ខេត្ត កណ្ដាល។អ្នកមីង ចឹម យេន ភូមិ មានទីលំនៅនាពេលបច្ចុប្បន្ននៅ ភូមិ ឧញ្ញ៉ាតី កោះ ឧញ្ញ៉ាតី ខេត្ត កណ្ដាល។

កៈ
ចឹងជាដំបូងជំរាបសួរលោកយាយខ្ញុំបាទមកពីរខាងសាកលវិទ្យាល័យបីបាយយូនៃសហរដ្ឋអាមេរិចហើយមានការអញ្ជើញដើម្បីមានការសំភាសន៍លោកអ្នកមីងអំពីពង្សប្រវត្តិតតើអ្នកមីងអាយអនុញ្ញាត្តិអោយសំភាសន៍អ្នកមីងពង្សប្រវត្តិអ្នកមីងបានដែលទេអ្នកមីង???

ខៈ ចាសបាន៕

កៈ
ចឹងថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំបានសំភាសន៍អ្នកមីងគឺជាថ្ងៃទី០២ខែ០៦(មិថុនា)ឆ្នាំ២០១៨ហើយធ្វើការសំភាសន៍ដោយរូបខ្ញុំបាទឈ្មោះគីមម៉េងហើយនាក់សំភាសន៍អ្នកមីងឈ្មោះអ្នកមីង ចឹម យេន
បាទហើយចឹងសំណួរដំបូងដែលខ្ញុំចង់សួរអ្នកមីងមានត្រគោលរបស់អ្នកពេញហាសចឹងផ្តើមឈ្មោះដំបូងខ្ញុំអាចស្គាល់ឈ្មោះរបស់អ្នកមីងបានដែលរឺទេអ្នកមីង???

ខៈ ចាសគឺខ្ញុំមានឈ្មោះ ចឹម យេន
ពីព្រោះអីនឹងគឺខ្ញុំបានដាក់ឈ្មោះនឹងគឺខាងឪពុករបស់ខ្ញុំនឹងហាសចាស៕

កៈ
បាទហើយចឹងសំរាប់ឆ្នាំនឹងថាតើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយសំរាប់ឆ្នាំនឹងអ្នកមីង???

ខៈ ចាសសំរាប់ឆ្នាំនឹងគឺខ្ញុំមានអាយុ ៥៩ ឆ្នាំហើយចាស ៕

កៈ
បាទហើយចឹងសំរាប់អ្នកមីងមានបានចាំថាអ្នកមីងបានកើតនៅឆ្នាំណាខែណាដែលរឺទេអ្នកមីង???

ខៈ ចាសនិយាយទៅគឺខ្ញុំមិនបានចាំនោះទេចាស៕

កៈ

បាទអ្នកមីងមិនបានចាំនោះទេបាទហើយសំរាប់អ្នកមីងមានទីកន្លែងកំណើតនៅកន្លែងណាដែលរឺទេអ្នកមីង???

ខៈ

ចាសសំរាប់ស្រុកកំណើតរបស់ខ្ញុំនឹងគឺនៅស្រុកកោះឧញ្ញាតីចាសនឹងសំរាប់ស្រុកកំណើតរបស់ខ្ញុំនឹងគឺរស់នៅទីកន្លែងនឹងតែម្តងហាសចាស៕

កៈ បាទហើយភូមិអ្វីហើយស្រុកអ្វីខេត្តអ្វីដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ភូមិស្រុកខេត្តនឹងគឺយើងនៅខេត្តកណ្តាលភូមិ ឧញ្ញាតី ស្រុកសាច់ កណ្តាល ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំទៅខាងនោះវិញហាសចាសគឺគ្មានមកខាងនេះទេចាសហើយសំរាប់ខាងកោះដាច់វិញនឹងគឺមកខាងមុខកំពូលវិញហាស៕

កៈ បាទហើយចឹងសំរាប់អ្នកមីងថាតើអ្នកមីងមានកូនចំនួនប៉ុន្មាននាក់ហើយអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំមានកូនចំនួន ៩
នាក់ហេហេហេហេហេចាសសំរាប់ជំនាន់នឹងវាមិនទៅនេះណាហើយសំរាប់កូនរបស់ខ្ញុំនឹងមានចំនួន ៩
នាក់នឹងសព្វថ្ងៃនឹងនូវតែ២នាក់នោះទេចាសពីព្រោះអីនឹងកូនរបស់ខ្ញុំនឹងទាំងអស់៧នាក់នឹងគឺគាត់បានរៀបអាពាហ៍ពិពាហ៍អស់ហើយចាស៕

កៈ បាទហើយចឹងសំរាប់អ្នកមីងមានបានចាំឈ្មោះកូនរបស់អ្នកមីងទាំង ៩
នាក់ដែលរឺទេអ្នកមីង???

ខៈ ចាសគឺខ្ញុំចាំហើយសំរាប់កូនរបស់ខ្ញុំគឺពួកកូនរបស់ខ្ញុំនឹងនៅទាំងអស់គ្នា៕

កៈ បាទហើយចឹងសំរាប់អ្នកមីងអាចប្រាប់ខ្ញុំបានទេហើយនឹងរាប់កូនអ្នកមីងទាំង ៩
នាក់ម្តងម្នាក់ម្តងម្នាក់បានដែលរឺទេអ្នកមីង???

ខៈ

ចាសឈ្មោះរបស់កូនរបស់ខ្ញុំនឹងដែលគាត់ដាក់ត្រគោលរបស់ឪពុកមែនដែលទេចាសសំរាប់កូនទី១របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហឿន យឿន
ហើយសំរាប់កូនទី២របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហឿន អឿន
ហើយសំរាប់កូនទី៣របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហឿន ហ៊្វូរ
ហើយសំរាប់កូនទី៤របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហឿន ហ៊្វូន
ហើយសំរាប់កូនទី៥របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ទូច សុភណ្ឌ

ហើយសំរាប់កូនទី៦របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហឿន សុខហៃ
ហើយសំរាប់កូនទី៧របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហឿន សុភាព
ហើយសំរាប់កូនទី៨របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហឿន សុខហេង
ហើយសំរាប់កូនទី៩របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហឿន សុខស្រីតូច
ចាសស្រីតូចចាសនឹងហើយគឺចប់ត្រឹមនឹងហើយចាស៕

កៈ
បាទហើយសំរាប់កូនរបស់អ្នកមីងទាំង៩នាក់អ្នកមីងមានកូនប្រុសប៉ុន្មានហើយនឹងស្រីចំនួនប៉ុន្មានដែលទៅអ្នកមីង???

ខៈ ចាសសំរាប់កូនរបស់ខ្ញុំទាំង ៩ នាក់នឹងគឺមានស្រី ៥ នាក់ ហើយនឹងប្រុស ៤ នាក់ចាស៕

កៈ បាទហើយចឹងកូនរបស់អ្នកមីង ៩ នាក់នឹង ប្រុស ៤ នាក់ហើយនឹងស្រី ៥ នាក់ថាតើពួកគាត់បានរៀបអាពាហ៍ពិពាហ៍អស់ចំនួន ៧នាក់ ហើយលូវនឹងនៅសល់ ប្រុស ១នាក់ ហើយនឹងស្រីនឹងចំនួន ១នាក់ដែលគាត់មិនទាល់បានរៀបអាពាហ៍ពិពាហ៍ចាស៕

កៈ បាទហើយចឹងគាត់បានរៀបអាពាហ៍ពិពាហ៍ ៧ នាក់ ហើយសំរាប់ ២នាក់ទៀតមិនទាល់បានរៀបអាពាហ៍ពិពាហ៍នោះទេមែនដែលទេអ្នកមីង???

ខៈ
ចាស២នាក់នឹងគឺគាត់មិនទាន់បានរៀបអាពាហ៍ពិពាហ៍នោះទេហើយម្នាក់នឹងគឺនៅរៀនហើយនឹងធ្វើការងារមួយចាស៕

កៈ
បាទហើយចឹងអរគុណច្រើនអ្នកមីងហើយចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើសំរាប់ស្វាមីរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ស្វាមីរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ឃិន ហឿន ចាស៕

កៈ បាទហើយចឹងសំរាប់ឆ្នាំនឹងថាតើគាត់មានអាយុប៉ុន្មានឆ្នាំហើយទៅអ្នកមីង???

ខៈ ចាសសំរាប់ស្វាមីរបស់ខ្ញុំនឹងគាត់អាយុ ៦៣ ឆ្នាំហើយចាស៕

កៈ បាទស្វាមីរបស់ ៦៣ឆ្នាំហើយចឹងបានន័យថាស្វាយរបស់អ្នកមីងប្អូនអ្នកមីងមែនដែលទេអ្នកមីង???

ខៈ ចាសគឺស្វាមីរបស់ខ្ញុំនឹងគឺគាត់បងខ្ញុំពីព្រោះអីនឹងគឺខ្ញុំមានអាយុទើបតែ ៥៩ ឆ្នាំនឹងចាសហើយសំរាប់ស្វាមីរបស់ខ្ញុំនឹងគឺគាត់មានអាយុ ៦៣ ឆ្នាំហើយចាសហើយសំរាប់ស្វាមីរបស់ខ្ញុំនឹងគឺគាត់បងខ្ញុំនឹង

៣ឆ្នាំចាសនឹងហើយហើយសំរាប់ខ្ញុំគឺខ្ញុំ ៥៩ ឆ្នាំ ចាសហើយសំរាប់គាត់ ៦០ ឆ្នាំជាងហើយចាសនិយាយទៅគឺគាត់ការមុខសីហាសចាស៕

ក៖
បាទហើយចឹងសំរាប់អ្នកមីងមានបានដឹងថាស្រុកកំណើតរបស់លោកពូគាត់មានទីកន្លែងកំណើតនឹងនៅកន្លែងណាដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់ស្រុកកំណើតរបស់ស្វាមីរបស់ខ្ញុំនឹងគឺគាត់នៅខាងភូមិព្រះវិហារសួគ៌ស្រុកព្រែកជញ្ជែងហើយសំរាប់ខេត្តគឺខេត្តនឹងដែលគឺជាខេត្តកណ្ដាលដែលហាសចាសគឺគាត់រស់នៅខាងនឹងដែលចាសហើយនិយាយទៅគឺគាត់រស់នៅខេត្តកណ្ដាលដូចគ្នាចាសហេហេហេហេអស់សួរចេះនិយាយនោះទេចាស៕

ក៖
បាទអស់អីទេអ្នកមីងហើយចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើអ្នកមីងធ្វើយ៉ាងមិចដែលទៅបានជាអ្នកមីងហើយនឹងលោកពូនឹងបានជួបនឹងគ្នាដែលទៅអ្នកមីងអាចប្រាប់ខ្ញុំបានដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំហើយនឹងប្ដីរបស់ខ្ញុំនឹងកាល់ដែលនៅក្នុងជំនាន់ពោលពតនឹងគឺយើងទាំង២នាក់បានដើរហើយនឹងធ្វើជាកងចល័តនឹងជាមួយនឹងគ្នាហើយគាត់ក៏បានឃើញខ្ញុំចឹងទៅហើយក៏បានដណ្ដឹងអោយចឹងទៅរួចហើយពួកពោលពតនឹងគឺគេបានរៀបចំ ២០គូហើយនឹង ៣០គូចឹងទៅហេហេហេហេ
និយាយវាមិននេះណាហើយដល់ពេលហើយចឹងទៅនៅពេលដែលយើងរៀបរួចហើយចឹងកូរចឹងហាសបានរៀនតាមផ្ទះហើយនឹងបានបាច់ផ្កាស្លាបាច់ផ្កាសីអីចឹងទៅហាសនឹងសំរាប់ខ្ញុំហាសចាសហើយពេលនឹងគឺយើងបានធ្វើមាន់ធ្វើអ្វីតាមផ្ទះចឹងទៅហើយពេលនឹងគឺយើងបានទៅយកបបរមកពីសហាករហ៍ហាសហើយនៅពេលដែលយើងនឹងយកមកគឺសែអីចឹងទៅចាសនឹងគឺជាថ្ងៃជំនាន់ពោលពតចាស៕

ក៖
បាទហើយសំរាប់អ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងលោកពូនៅក្នុងឆ្នាំណាដែលទៅលោកពូ???

ខ៖
ចាសសំរាប់មួយនឹងគឺខ្ញុំបានចប់ពីជំនាន់ពោលពតនឹងហាសគឺខ្ញុំមិនសូវជាចាំដែលនោះទេចាសនឹងហើយគឺនៅក្នុងឆ្នាំ ១៩៧៩
ហាសហើយសំរាប់ចប់ពីជំនាន់ពោលពតនឹងគឺជាឆ្នាំអ្វីដែលទៅហេហេហេហេចាសសំរាប់ខ្ញុំគឺខ្ញុំមិនសូវជាចាំនោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងលោកពូហើយចឹងថាតើអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងលោកពូដោយសេចក្ដីស្រឡាញ់រឺក៏ដោយគេបង្ខំដែលទៅអ្នកមីង???

ខ៖
ចាសនៅពេលដែលខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងប្ដីរបស់ខ្ញុំនឹងគឺដោយស្នាក់ចិត្តហើយនឹងតាមឪពុកហើយនឹងម្ដាយចាសនិយាយទៅឪពុកហើយនឹងម្ដាយរបស់យើងនឹងគឺគាត់ជាអ្នកទុក្ខដាក់អោយយើងចឹងហាសចាសហើយយើងនឹងក៏តាមគាត់ចឹងទៅហាសចាស៕

ក៖
បាទហើយចឹងអរគុណច្រើនអ្នកមីងចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើនៅពេលដែលអ្នកមីងនៅជាវ័យកុមារអ្នកមីងថាតើអ្នកមីងបានរៀនសូត្រដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំកាល់ដែលខ្ញុំរស់នៅក្នុងស្រុកកោះនឹងគឺថាវាចេះតែគ្រាប់បាញ់ទៅលិចទៅកើតហាសនៅពេលនឹងគឺខ្ញុំបានរត់ទៅនៅចុងកោះហើយនឹងរត់ទៅព្រៃកលាបហាសគឺរត់តាមទូតហើយនិយាយគឺខ្ញុំនឹងមិនបានរៀនសូត្រនោះទេចាសដល់ពេលដែលនៅក្នុងជំនាន់ពោលពតគឺគេបានអោយរៀនដែលក៏ប៉ុនតែខ្ញុំរៀនមិនបានចេះហើយនឹងចាំនោះទេចាសហេហេហេហេនិយាយទៅចប់តែម្ដងចាសក៏ប៉ុនតែសំរាប់រឿងលុយកាក់អីនឹងគឺមិនចេះខ្វះនោះទេចាសក៏ប៉ុនតែសំរាប់ការរៀនសូត្រវិញគឺមិចេះតែម្ដងហើយយើងមិនបានដឹងថាដាក់អ្វីទៅជាអ្វីនោះទេចាសហើយនៅពេលដែលគេបានអោយរៀននៅក្នុងជំនាន់ពោលពតនឹងគឺគេបានអោយអាការះកម្មនឹងហាសចាសនិយាយទៅនៅតែមិនចេះហេហេហេហេហេហើយប្រសិនជាអោយយើងនឹងទៅលីដីធំធំគឺលីបានចឹងហាសពីព្រោះអីនឹងនៅពេលនឹងគឺយើងហូបមិនបានគ្រាប់គ្រាន់ហើយសំរាប់បបរនឹងគឺវាវាយកខ្លួតនឹងហើយណាមួយទៀតបបរនឹងវាបានស្អុយហើយយើងនឹងចេះតែស៊ីចឹងទៅហើយស៊ីនឹងគឺស៊ីអោយតែតឹងពោះចឹងទៅចាសនឹងហើយកាល់ដែលនៅជំនាន់ពោលពតនឹងហាសចាសហើយសំរាប់ការងារលើដីនឹងយប់នឹងក៏យើងនឹងលីដែលអោយតែគេនឹងបានតំរូវអោយនឹងធ្វើដូចថាល្ងូវនឹងគឺគេអោយយើងទៅលើកដីទៅដាក់នៅមុខព្រួនណាហើយនឹងលើកដាក់ប្រឡាយកន្លែងណាចាសហើយនៅពេលដែលគេបានមកចឹងគឺគេបានប្រាប់មេកងមេអីចឹងហើយប្រាប់ប្រធានភូមិអីចឹងហើយសំរាប់ចោបកាប់នឹងលីដាក់នឹងស្មារនឹងគឺយើងនឹងបានលីទៅហើយចាសនិយាយទៅទាំងស្រីហើយនឹងទាំងប្រុសនឹងហាសចាសនិយាយទៅវានឿនវាហាស់ពីនឿនហើយនឹងចុបចាប់ហើយវាបានស្ដីអោយហើយវាពួកវានឹងសុទ្ធតែថាអោយខ្ញុំនឹងមកពីខាងមូលដ្ឋានថ្មីពីព្រោះអីនឹងពួកវាសុទ្ធតែចាស់ចាស់ចឹងហាសហើយសំរាប់បបរអីនឹងគឺវាបានដាក់មិនអោយយើងនឹងបានឃើញកំរង់នោះទេហើយសំរាប់ខាងយើងគឺជាខាងមូលដ្ឋានថ្មីគឺពួកវាមិនអោ

យដាក់ពេញអោយនោះទេចាសហើយសំរាប់ខាងមូលដ្ឋានចាស់ចាស់នឹងគឺពួកវាដាក់អោយពេញពេញអោយចឹងហាសហើយនិយាយទៅគឺខ្ញុំនឹងខឹងគេខ្លាំងណាស់សំរាប់កាលនឹងហាសចាសពីព្រោះអីនឹងគឺយើងបានធ្វើការងារជាមួយនឹងគេដែលក៏ប៉ុនតែនឹងគឺបានដាក់អោយយើងនឹងបានតែបន្តិចនឹងក៏យើងនឹងខឹងគេដែលហេហេហេហេហេចាសកាលជំនាន់នឹងចេះតែខឹងគេចាស៕

កៈ
បាទអ្នកមីងហើយចឹងកាល់នៅក្នុងជំនាន់នឹងសំរាប់អ្នកមីងអ្នកមីងគឺមិនបានរៀនសូត្រទេមែនដែលទេអ្នកមីង???

ខៈ
ចាសសំរាប់នៅក្នុងជំនាន់នឹងគឺខ្ញុំមិនបានរៀននោះទេពីព្រោះអីនឹងគឺខ្ញុំរវល់រត់ពីគ្រាប់ប្លោងហើយសំរាប់ខ្ញុំនឹងគឺខ្ញុំរត់ទៅលិចហើយនឹងទៅកើតហើយសំរាប់ជំនាន់នឹងគឺចេះតែបើកទូតនឹងទៅលិចហើយនឹងទៅកើតចឹងទៅចាសហើយសំរាប់ផ្ទះរបស់ខ្ញុំនឹងកាល់ពីមុខនឹងគឺនៅភូមិខាងនោះទេហើយមកដល់លូវនឹងនៅពេលដែលឪពុករបស់ខ្ញុំនឹងបានចែកដីអោយចឹងហាសធ្វើចំការហើយខ្ញុំនឹងក៏បានធ្វើផ្ទះនឹងនៅកន្លែងនឹងតែម្ដងទៅចាសនឹងហើយដល់ពេលហើយចឹងក៏ខ្វល់ទៅរស់នៅឯងភូមិវិញហើយដល់ពេលដែលយើងមានគោមានអីចឹងទៅយើងនឹងក៏បានធ្វើចំការធ្វើអីចឹងទៅចាស៕

កៈ
បាទហើយចឹងនៅក្នុងជំនាន់នឹងគឺគេបានបាញ់គ្រាប់ប្លោងនឹងថាតើអ្នកមីងបានរស់នៅជាមួយនឹងឪពុកហើយនឹងម្ដាយរបស់អ្នកមីងនឹងរឺក៏គេបានបំបែកពីគ្នាដែលអ្នកមីង???

ខៈ
ចាសនិយាយទៅគឺអត់បានបំបែកនោះទេគឺរស់នៅជាមួយនឹងឪពុកហើយនឹងម្ដាយរបស់ខ្ញុំចាសហើយអត់បានរៀនអត់បានអីនឹងគឺដោយសារចឹងចាសពីព្រោះអីនឹងគឺយើងបានរត់ទៅលិចហើយនឹងរត់ទៅកើតហាសគឺរស់នៅជាមួយនឹងឪពុកហើយនឹងម្ដាយដល់ពេលដែលចឹងទៅនៅពេលដែលបែកឆ្នាំ ១៩៧៥
នឹងបានគេនឹងជំលាស់យើងនឹងទៅរស់នៅខាងនឹងគឺជាព្រះវិហារសួគ៌ព្រះហារចាស់ចឹងទៅចាសគឺគេបានជំលាស់ទៅរស់នៅទីកន្លែងនឹងតាំងពីតូចហាសចាសហើយសំរាប់ខ្ញុំហើយសំរាប់ខ្ញុំកាល់នឹងគឺខ្ញុំនៅមានអាយុ១៨ឆ្នាំរឺក៏១៥ឆ្នាំអីនឹងចាសហើយទុំរាមតែដល់ពេលនឹងគឺមានអាយុ១៦ឆ្នាំហាសចាសសំរាប់កាល់នឹងគឺ ៣ឆ្នាំ ៨ខែ ២០ថ្ងៃ
គឺចប់ជំនាន់ពោលពតហើយចាសហើយនៅពេលដែលខ្ញុំមានអាយុ១៩ឆ្នាំគឺមកឡូវចឹងហាសចាសហើយនៅពេលដែលគឺគេបានអោយខ្ញុំនឹងបានរៀបចំមួយគូបមួយគូបហើយសំរាប់ពួកវានឹងគឺមិនអោយយើងនឹងបានរស់នៅជាមួយនឹងម្ដាយហើយនឹងឪពុករបស់យើងនោះទេចាសហើយគេទាំងអស់នឹងគឺបានចាប់បំបែកយើងហើយនៅពេលដែលគេបានបំបែកយើងហើយចឹងគឺគេបានអោយយើងនឹងទៅធ្វើរោងសំរាប់មួយគ្រួសារមួយគ្រួសារហើយនឹ

ងមួយរោងមួយរោងមានតែមួយគ្រែគ្រែចឹងហាសចាសហើយជិតជិតគ្នាចឹងទៅហើយសំរាប់ពួកវានឹងគឺមិនអោយយើងនឹងបានរស់នៅជាមួយនឹងគ្រួសាររបស់យើងនោះទេចាសហើយនៅពេលដែលគេបានតំរូវអោយយើងនឹងទៅណាចឹងដូចជាអោយយើងនឹងទៅលើកដីលើកអីចឹងទៅគឺយើងគឺគេបានហៅកងចល័តយើងនឹងទៅចឹងទៅហើយនៅពេលដែលទៅនឹងគឺគេបានអោយទៅទាំងប្ដីហើយនឹងប្រពន្ធទាំងប្ដីហើយនឹងប្រពន្ធចឹងចាស៕

ក៖
បាទហើយចឹងនៅពេលដែលគេបានបំបែកឪពុកហើយនឹងម្ដាយរបស់អ្នកមីងចេញពីអ្នកមីងចឹងបានន័យថាអ្នកមីងត្រូវតែរស់នៅតែម្នាក់ឯងហើយមែនដែលទេអ្នកមីងហើយចឹងសំរាប់គេគឺគេមានអោយអ្នកមីងធ្វើការងារអ្វីដែលពិបាក់ជាងនឹងដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺគេបានអោយនាងខ្ញុំនឹងបានលីដីលីនឹងហាសចាសហើយនឹងកាប់ដីអីទាំងអស់ហើយសំរាប់កងចល័តនឹងគឺគេបានស្ទុងស្រែស្ទុងអីនឹងហាសក្មួយហើយនិយាយទៅគឺគ្មានទំនេរនោះទេចាសហើយសំរាប់ជំនាន់នឹងគឺគ្មានធ្វើអ្វីនោះទេគ្រាន់តែលើកប្រឡាយហើយនឹងលើកដីហើយនឹងលីប្រឡាយនឹងហើយនឹងស្ទុងស្រែហើហាយនឹងលីដីទាំងអស់នឹងចាសហើយនឹងវ៉ៃយកណ្ដាលអីទាំងអស់នឹងហាសចាសអត់មានធ្វើការងារណាដែលធូន់អីនោះទេចាសហើយនឹងចាប់ចងក្ដាប់អីនឹងគឺគ្មាននោះទេគ្រាន់តែយើងនឹងពិបាក់នឹងហូបចុចវាមិនពេញលេញអីចឹងហាសហើយសំរាប់ម្ហូបអីនឹងគឺយើងហូបមិនបានឆ្អែតអីចឹងហាសចាសហើយយើងនឹងចេះតែទ្រាំតស៊ូរអីចឹងទៅហើយណាមួយទៀតមានថ្ងៃណាអីចឹងទៅគឺយើងបានសុំគេនឹងបានចូលផ្ទះអីចឹងទៅហើយមកកោះដំឡូរយកមកស្ងោរអីចឹងទៅដើម្បីយកទៅផ្ទះចឹងទៅហើយសំរាប់ឪពុកដែលគាត់នឹងបាននៅផ្ទះអីចឹងហាសគឺគាត់បានដាំដំឡូរអីបន្តិចអីចឹងទៅដែលបានដាំនៅផ្ទះចឹងហាសចាសនិយាយទៅវាជាដំឡូរជ្វារចឹងហាសដល់ពេលចឹងមកដល់ពេលព្រលឹបព្រលឹបបានចូលមកគឺជាមេកងដូចជាប្រធានភូមិរបស់គេចឹងហាសចាសហើយយើងបានសុំគេហើយយើងបាននិយាយថាបងអើយខ្ញុំសុំទៅយកដំឡូរស្ងោរអីចឹងទៅហើយពេលនឹងគឺគេបានអោយយើងបានចូលចឹងទៅហើយនៅពេលដែលគេបានអោយចូលចឹងទៅហើយសំរាប់ពេលនឹងគឺយើងនឹងបានដើរគឺយើងគ្មានខ្លាចនោះទេនឹងសំរាប់ពេលយប់ហាសហើយសំរាប់ម្នាក់ឯងដល់ម៉ោង៧រឺក៏៨យប់អីនឹងយើងបានដើរម្នាក់ហើយនឹងចេញពីផ្ទះនឹងទៅដល់ការដ្ឋានកន្លែងកងចល័តរបស់គេចឹងហាសហើយក៏គ្មានអ្វីដែលហើយសំរាប់យើងចេះតែហ៊ានដើរដែលហេហេហេហេហើយសំរាប់ល្ងូវនឹងប្រសិនជាអោយខ្ញុំនឹងបានដើរម្នាក់ឯងអីនឹងគឺមិនហ៊ាននោះទេចាស៕

ក៖ បាទហើយសំរាប់អ្នកមីងចង់កងចល័តនឹងទៅធ្វើអ្វីដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំទៅកន្លែងកងចល័តនឹងគឺខ្ញុំទៅនឹងសំរាប់ដេកនៅកន្លែងកងចល័តនឹងចូលផ្ទះអីចឹងដូចថានៅពេលដែលយើងនឹងបានមកពីស្ទុងអីចឹងហើយនៅពេលដែលយើងបានយើ

ញមេកងនឹងគឺយើងនឹងបានសុំគេនឹងបានចូលដើម្បីកោសដំឡូរស្វោររួចហើយគឺគេបាន ហៅយើងនឹងដេកនៅកន្លែងនឹងវិញចាសហើយនៅពេលដែលយើងបានដេកនឹងគឺបានចំនួន១យប់នឹងបានយើងនឹងបានដើរទៅផ្ទះឪពុករបស់យើងវិញចាស៕

កៈ

បាទហើយចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើនៅពេលដែលគេបានអោយអ្នកមីងធ្វើការងារដែលធ្ងន់ធ្ងរអីចឹងក៏ដូចជាជីកប្រឡាយហើយនឹងរ៉ែកទឹកអីចឹងហើយនឹងធ្វើការងារអ្វីផ្សេងៗនឹងថាតើអ្នកមីងមិនបានហូបគ្រាប់គ្រាន់ហើយសំរាប់អ្នកមីងមានកំលាំងនឹងធ្វើការងារទាំងអស់នឹងដែលរឺទេអ្នកមីង???

ខៈ

ចាសសំរាប់ខ្ញុំនៅពេលដែលគេបានប្រើខ្ញុំនឹងគឺខ្ញុំនឹងចេះតែខំប្រឹងនឹងគេនឹងឯងចឹងទៅហើយទោះបីជាយើងហូបមិនបានឆ្អែតនឹងក៏យើងខំប្រឹងនឹងធ្វើការងារចឹងទៅហើយប្រសិនជាយើងនឹងមិនធ្វើការងារទាំងអស់នឹងទេគឺគេនឹងថាយើងនឹងហើយថាយើងនឹងឈឺអីបន្តិចបន្តួចគឺយើងនឹងមិនហ៊ាននឹងកហុសគេនោះទេហើយចឹងហើយគឺយើងចេះតែខំប្រឹងនឹងធ្វើចឹងទៅហាសចាសហើយយើងនឹងក៏គ្មានហ៊ាននឹងឈប់ដែលចាសដែលនៅជំនាន់ពោលពតហាសហើយនៅពេលដែលយើងហូបមិនបានឆ្អែតនឹងក៏យើងនឹងមិនហ៊ានថាហូបមិនបានឆ្អែតដែលហាសចាសនិយាយទៅគឺវាជាទូទៅហើយពីព្រោះអីនឹងគឺគេមានគ្រាប់គ្នាចឹងទៅហើយហើយមិនមែនថាមួយហូបបានឆ្អែតហើយនឹងមួយផ្សេងទៀតនឹងបានហូបឆ្អែតណានិយាយទៅហូបមិនឆ្អែតគ្រាប់តែគ្នានឹងហាសចាសហើយសំរាប់មួយក្រុមនឹងដឹងតែមានចំនួន១០នាក់ហើយចាសហើយសំរាប់សំល្លរមួយឆ្នាំងនឹងគឺគេបានដាក់មកអោយយើងចឹងហើយគឺគេបានចែកអោយមកដល់ខ្លួនចឹងទៅហើយសំរាប់ចឹងដែលនៅពេលដែលយើងហូបដែលអ្នកណាដែលគេហ៊ាននឹងគឺគេបានហូបឆ្អែតហើយសំរាប់យើងនឹងគឺយើងមិនហ៊ាននឹងគឺយើងហូបមិនបានឆ្អែតហើយសំរាប់យើងមើលគេនឹងឃើញគេហូបបានវញ្ញែរញ្ញែចឹងហាសហើយប្រសិនជាយើងនឹងខំប្រឹងនឹងហូបពេកនឹងក៏វាមិនកើតដែលចឹងហាសគឺវាខ្មាសគេនឹងហាសពីព្រោះអីនឹងយើងទាំងអស់គ្នានឹងបានហូបជុំគ្នាហាសហើយសំរាប់យើងមិនចេះតែហូបឯងណាហើយដាក់គ្រាប់គ្រាប់ណាចាសហើយនៅពេលដែលយើងនឹងហូបនឹងគឺយើងចេះមើលគេដែលចឹងហាសមិនមែនចេះតែហូបនោះទេចាសហើយសំរាប់អ្នកខ្លះនឹងគឺគេហូបនឹងមិនដឹងអីនោះទេហើយខំប្រឹងហូបយ៉ាងមិចអោយតែខ្លួនឯងនឹងបានឆ្អែតហាសចាសហើយគឺគេមិនបានគិតពីគេអាក្រុមទី៦នឹងគឺគេបានជុំគ្នាហូបបានមើលគេមើលឯងហើយសំរាប់អ្នកខ្លះទៀតនឹងហូបហូបអោយបានតែឆ្អែតនោះទេចឹងហាសនិយាយទៅគឺវាមានមួយមាន២ចឹងហាសដែលពួកគេនឹងហូបមិនដឹងអីចឹងហាសចាស៕

កៈ

បាទហើយចឹងនៅពេលដែលអ្នកមីងហូបមិនបានឆ្អែតចឹងសំរាប់អ្នកមីងមានជំងឺឈឺស្កាក់អីដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំកាល់ដែលនៅក្នុងជំនាន់ពោលពតនឹងគឺវាមិនជាសូវឈឺដែលចឹងហាសគ្រាន់តែវាហាត់អីចឹងហើយដូចថាវានៅក្នុងជំនាន់នឹងវាគ្មានជាតិគីមីអីចឹងហាសចាសហើយសំរាប់យើងនឹងគឺយើងហូបតែធម្មជាតិចឹងទៅហើយសំរាប់បន្លែរអីនឹងគឺមិនដែលគេបានដាក់ថ្នាំអីនោះទេបាទហើយមកដល់នឹងគឺមានមនុស្សច្រើនណាស់ដែលឈឺហាសហើយសំរាប់ខ្ញុំសព្វថ្ងៃនឹងគឺខ្ញុំឈឺតែជើងដែលនឹងហាសហើយខ្ញុំចេះតែខំប្រឹងនឹងទៅលក់ដែលចឹងហាសហើយគេបាននិយាយថាខ្ញុំនឹងបានពុតឆ្អឹងដែលហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងបានទិញថ្នាំមកអោយខ្ញុំនឹងមកញ៉ាំនឹងគឺមួយគ្រាន់នឹងតំម្លៃ ៥០ ដុល្លារ
ហាសហើយសំរាប់ជើងរបស់ខ្ញុំនឹងគឺវានៅតែប៉ុននឹងនោះទេពីព្រោះអីនឹងគឺខ្ញុំបានលាបបាន ២កំប៉ុងហើយចឹងហាសហើយសំរាប់ថ្នាំនឹងគឺវាបំបាក់ការឈឺចាប់ហាសចាសនិយាយទៅគឺវាអន់ឈឺចាប់ជាងមុខវាសហើយសំរាប់មុខនឹងគឺមានភាពឈឺចាប់ហាសហើយសំរាប់សព្វថ្ងៃនឹងនិយាយទៅមិនមែនថាវាមិនឈឺនោះទេគឺយើងនឹងឈឺពេញអស់ហើយនិយាយទៅពីមុននឹងគឺយើងមិនដែលសូវឈឺនោះទេហើយសំរាប់ពីមុននឹងនៅពេលដែលយើងកោសខ្យល់ហើយហើយចាសហើយសំរាប់ថ្នាំនឹងក៏មិនដែលបានសូវលែបដែលហាសចាសហើយសំរាប់កូនរបស់ខ្ញុំនឹងវាគ្រាប់គ្នានឹងគឺវាថានៅពេលដែលគេឈឺហើយនឹងឆ្លងទន្លេរអីនឹងហើយនឹងទៅពេទ្យអីនឹងគឺគ្មាននោះទេចាសហើយពួកវានឹងគឺឆ្លងទន្លេរនៅតែផ្ទះនោះគឺយើងបានហៅពេទ្យនឹងមកជួយអោយបង្កើតនៅផ្ទះរបស់យើងនឹងហាសចាសហើយក៏មិនដែលបានមកស្គាល់ពេទ្យណាដែលហាសចាសហើយមិនដែលបានឃើញពេទ្យណាដែលហាសចាសហើយហៅទៅពេទ្យអីគឺគ្មាននោះទេចាសនិយាយទៅគឺគ្មានសោះចាស៕

ក៖
បាទហើយចឹងសំរាប់នៅក្នុងជំនាន់នឹងសំរាប់អ្នកមីងបានធ្វើការងារខ្លាំងក៏ប៉ុនតែអ្នកមីងមិនជាសូវឈឺនោះទេមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅនៅក្នុងជំនាន់នឹងគឺខ្ញុំនឹងមិនសូវជាឈឺអ្វីនោះទេពីព្រោះអីនឹងគឺខ្ញុំនឹងបានធ្វើការងារនឹងខ្លាំងហើយនឹងហាត់នឿនហាសហើយយើងនឹងក៏បានទ្រាំនឹងរហូតដល់ម៉ោងនឹង ១២
ថ្ងៃត្រង់ហើយសំរាប់យើងមិនមែនិយាយថាយើងនឹងមិនខ្ជៀននោះទេតែយើងនឹងចេះតែមើកម៉ោងមើលចាសគឺយើងមើលថ្ងៃទេនិយាយទៅនៅក្នុងជំនាន់នឹងគឺយើងគ្មានម៉ោងនឹងសំរាប់មើលនោះទេចាសហេហេហេហេហើយយើងនឹងមើលតែថ្ងៃទេហាសហើយពេលនឹងយើងក៏បាននិយាយថាថ្ងៃអើយហេតុអ្វីបានជាយូរម្លេះសំរាប់ខ្ញុំនឹងគឺខ្ញុំបានឃ្លានណាស់ហើយសំរាប់ពេលនឹងគឺគ្មាននាក់ទៅគឺមានតែយើងនឹងទៅតែឯងចឹងហាសចាសសំរាប់ជំនាន់នឹងនិយាយទៅគឺវាមានភាពពិបាក់ហើយនឹងវេទនាដែលក៏ប៉ុនតែនឹងគឺថាយើងចេះតែទ្រាំនឹងគេនឹងឯងចឹងទៅហាសចាសពីព្រោះអីនឹងសំរាប់គេក៏ចឹងហើយសំរាប់យើងនឹងក៏វាចឹងដែលហាសចាស៕

ក៖
បាទហើយចឹងសំរាប់នៅក្នុងជំនាន់នឹងនៅពេលដែលអ្នកមីងហូបមិនបានគ្រាប់គ្រាន់ចឹង ហើយសំរាប់អ្នកមីងធ្វើការងារធ្ងន់ទៀតហើយសំរាប់អ្នកមីងមើលទៅយ៉ាងមិនបានដឹងថា ថ្ងៃត្រង់នឹងគឺគេបានអោយបាយយើងនឹងសំរាប់ហូបហាសអ្នកមីង???

ខ៖
ចាសនិយាយទៅដូចថានៅពេលដែលគេបានដល់ម៉ោងនឹងគឺថ្ងៃត្រង់ហើយនឹងចំក្បាលរបស់យើងនឹងហាសបានបានបាយនឹងសំរាប់ហូបហាសចាសហើយនិយាយទៅដូចថាសំរាប់ថ្ងៃចាំងមកហើយនឹងមកកន្លែងយើងនឹងបានគេបានបញ្ចាប់យើងចឹងហាសគឺឈប់ធ្វើការងារនិយាយទៅគឺដល់ម៉ោង
១២ថ្ងៃត្រង់នឹងតែម្ដងហាសចាសហើយនិយាយទៅគឺយើងនឹងច្បាស់តែម្ដងគឺដល់ម៉ោង១២នឹងហាសចាសហើយសំរាប់ស្រមោររបស់យើនឹងបានជាន់ជើងរបស់យើងនឹងគឺថាយើងបានឈប់ហាសចាសហើយនិយាយទៅប្រសិនជាប្រៀបធៀបមកដល់លូវនឹងគឺថានៅពេលដែលយើងនឹងចង់ហូបពេលណាគឺយើងនឹងបានហូបពេលនឹងហើយចាសហើយនៅពេលដែលយើងនឹងបានឈរនឹងគឺដឹងតែមានស្រមោររបស់យើងនឹងគឺវាបានចូលខ្លួនរបស់យើងនឹងតែម្ដងហាសចាសហើយយើងចង់ជាន់ស្រមោលហាសបានយើងនឹងបានឈប់ចាស៕

ក៖
បាទហើយចឹងថាតើគេមានបានអោយអ្នកមីងធ្វើការងារអ្វីទៀតដែលរឺទេក៏ដូចជាទៅកាប់ឡើងត្នោតអីនឹងដើម្បីយកទឹកអីដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺគ្មាននោះទេចាសសំរាប់ស្រីស្រីនឹងគឺគេមិនបានអោយឡើងត្នោតនោះទេចាសសំរាប់ដើមត្នោតដើមអីនឹងគឺគ្មាននោះទេនិយាយទៅយើងគិតតែពីលើកដីហើយនឹងប្រឡាយហើយនឹងជីកទ្រនុំហើយនឹងជីកប្រឡាយនឹងហាសនឹងសំរាប់ស្រីស្រីដែលជាកងចល័តហាសចាសនឹងគឺសំរាប់ជំនាន់ពោលពតហើយសំរាប់នៅចំកណ្ដាលនឹងដែលថាអោយអ្នកទាំងអស់នឹងគឺអោយគេបានស្ទូងស្រូវសំរាប់មួយហិតតា៣តោននឹងគឺមិនខ្វះនោះទេចាសហើយនិយាយទៅដឹងតែស្ទូងនឹងតែម្ដងហាសចាសហើយសំរាប់បាយហើយនឹងទឹកនឹងគឺយើងនឹងយកទៅទៅចឹងទៅចាសហើយសំរាប់ល្ពៅហើយយើងដាំបាយហើយដាក់ល្ពៅដាក់ចឹងទៅហើយសំរាប់ខ្ញុំនឹងគឺខ្ញុំគ្រាប់សាប់ដែលកាល់ខ្ញុំនឹងនៅវ័យកុមារនឹងហាសគឺគេបានអោយខ្ញុំនឹងបានដាំបាយដាំអីដែលចឹងហាសហើយសំរាប់ខ្វះអីនឹង១០ខ្វះនឹងអោយដាំតែ២នាក់នោះទេហើយសំរាប់ខ្វះ២ចឹងនឹងសំរាប់ចង្ក្រានដែលនៅខាងនេះចឹងគឺមានខ្វះ១០ចឹងទៅហាសចាសហើយនិយាយទៅ១ជួរ១០ ១ជួរ១០
ពីព្រោះអីនឹងគឺគេបានធ្វើសង្គ្រានវែនហាសចាស៕

ក៖ បាទហើយសំរាប់១០ខ្វះនឹងថាតើហូបទាំងអស់នឹងហូបប៉ុន្មានដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់១០ខ្ទះនឹងគឺហូបគ្នារាប់រយនាក់ហាសចាសនឹងសំរាប់កងចល័តហាសនិយាយទៅគឺច្រើននាក់ខ្លាំងណាស់ចាសនិយាយទៅដូចមួយឃុំពីព្រៃកជញ្ជែងទៅស្វាយមាសនឹងហើយនឹងខាងព្រះវិហារសួត័ហើយនឹងកណ្តាលហើយនឹងមានព្រះវិហារសួត័តូចហើយនឹងព្រះវិហារធំអីទាំងអស់នឹងហើយសំរាប់ស្វាយមាសនឹងគឺគេមានមួយក្រុមអីចឹងទៅចាសនិយាយទៅគឺខាងព្រះហារសួត័នឹងតែម្តងចាសហើយសំរ៉ាបខាងនឹងគឺដោយខ្លួននោះទេចាសនិយាយទៅគឺភូមិរបស់គេនឹងវាផ្សេងហើយសំរាប់ខាងរបស់ខ្ញុំនឹងគឺខាងនេះនឹងតែម្តងចាសនឹងសំរាប់ខាងព្រះហារសួត័ហាសដែលនៅខាងស្វាយមាសចាសហើយសំរាប់មួយនឹងគឺគេបានហៅកន្លែងនឹងថាព្រះហារសួត័ត្បូរហើយនឹងព្រះហារសួត័ខាងជើងចាសនឹងហើយហើយសំរាប់ព្រះហារសួត័ខាងត្បូងនឹងដែលហើយនឹងសំរាប់ខាងតាកែវចាសហើយនឹងគឺមកខាងព្រះហារសួត័នឹងតែម្តងហាសចាសនិយាយទៅ៤រឺក៏៥ភូមិហាសបានហើយបានចូលមកខាងព្រះហារសួត័នឹងទាំងស្រីហើយនឹងទាំងប្រុសហើយគឺគេបានមកជុំគ្នាចឹងទៅហាសចាសហើយនៅពេលដែលគេដល់ម៉ោងដេកនឹងគឺគេបានធ្វើរោងសំរាប់ប្រុសប្រុសនឹងគឺធ្វើនៅខាងកើតវត្តហើយសំរាប់ស្រីស្រីនឹងគឺនៅក្នុងវត្តព្រះហារសួត័នឹងតែម្តងចាសនិយាយទៅគឺគេបានធ្វើរោង២រឺក៏៣ជួរហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលនឹងគឺគេបានអោយប្រុសនៅដោយប្រុសហើយសំរាប់ស្រីគឺនៅដោយស្រីមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺគេបានអោយប្រុសនៅដោយប្រុសហើយសំរាប់ស្រីគឺនៅដោយស្រីគឺគេមិនបានអោយនៅជិតគ្នានោះទេចាសក៏ប៉ុនតែនឹងអោយតែដល់ម៉ោង៥ព្រឹកឡើងចឹងទៅគឺគេបានអោយដំរង់ជួរប្រុសហើយនឹងស្រីនឹងគឺនៅជិតជិតគ្នាហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងនៅក្នុងជំនាន់នឹងដែលអ្នកមីងនៅក្មេងចឹងគេបានអោយអ្នកមីងគឺគេបានអោយអ្នកមីងនឹងបានរស់នៅឆ្ងាយពីឪពុកហើយនឹងម្តាយរបស់អ្នកមីងហើយចឹងសំរាប់អ្នកមីងមាននឹកឪពុកហើយនឹងម្តាយរបស់អ្នកមីងដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺខ្ញុំនឹកឪពុកហើយនឹងម្តាយរបស់ខ្ញុំនឹងគឺខ្លាំងណាស់ហើយសំរាប់នឹកមួយនឹងគឺនៅពេលដែលយើងនឹកឪពុកហើយនឹងម្តាយរបស់យើងចឹងទៅគឺយើងនឹងបានសុំគេនឹងបានមកផ្ទះចឹងហាសចាសនិយាយទៅបាន១ថ្ងៃអីចឹងទៅហើយនៅពេលដែលយើងទៅធ្វើការងារចឹងទៅបានដើរនឹងពាះផ្លូវកែងប្រឡុះផ្ទះចឹងទៅហើយយើងបានសូមប្រធានក្រុមនឹងបានចូលផ្ទះហើយយើងបាននិយាយថាបងប្រធានអើយខ្ញុំសូមចូលផ្ទះដើម្បីបានកោសដំឡូរនឹងសំរាប់ហូបអីចឹងទៅហាសហើយប្រាប់ប្រធាននឹងចឹងទៅគឺគេបានអោយ

យើងនឹងបានចូលចឹងទៅហើយទុំរាមបានចូលនឹងហើយនឹងយើងបានកោសហើយនឹងបានស្ងោរបានឆ្អិនហើយនឹងគឺដល់ម៉ោង៨ល្ងាចឯងនោះហើយយើងបានដើរទៅកន្លែងទៅរកកន្លែងសំរាប់ដេកហើយនៅពេលដែលយើងបានទៅនឹងគឺយើងបានដេកនៅព្រះហារស្ងួត៏ចឹងទៅចាស៕

កៈ
បាទហើយចឹងសំរាប់ដើរដល់ពីម៉ោងប៉ុន្មានទៅដល់ម៉ោងប៉ុន្មានបានហើយទៅអ្នកមីង???

ខៈ
ចាសនិយាយទៅគឺយើងកោសតែមួយភ្លេចនោះទេចាសគ្រាន់តែស្ងោរហើយយើងនឹងបានអង្គុយលេងជាមួយនឹងឪពុកហើយនឹងម្ដាយរបស់យើងចឹងទៅហាសចាសហើយសំរាប់ខ្ញុំខ្ញុំគ្មានម្ដាយនោះទេពីព្រោះអីនឹងគឺម្ដាយរបស់ខ្ញុំនឹងគឺគាត់បានស្លាប់តាំងពីសង្គមចឹងហាសចាសហើយសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺគាត់បានស្លាប់នៅអាយុ ៥០ ឆ្នាំដល់ពេលចឹងទៅគឺសំរាប់ខ្ញុំគឺខ្ញុំកំព្រាម្ដាយខ្ញុំនឹងតាំងពីខ្ញុំនឹងនៅតូចចឹងហាសចាសហើយសំរាប់ដល់ពេលនឹងគឺនៅតែឪពុករបស់ខ្ញុំនោះទេហើយសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់ក៏មិនយកប្រពន្ធទៀតដែលហាសចាសហើយគាត់ចិញ្ចឹមកូនរហូតហើយរហូតដល់គាត់នឹងបានចូលមកស្រុកវិញចឹងហាសហើយសំរាប់គាត់បានស្លាប់នៅពេលដែលគាត់នឹងបានចូលស្រុកហាសចាសនឹងសំរាប់ឪពុករបស់ខ្ញុំនឹងហាសចាសនឹងហើយ៕

កៈ
បាទហើយចឹងចង់សួរអ្នកមីងមួយទៀតថាឪពុកហើយនឹងម្ដាយរបស់អ្នកមីងគាត់ទាំង២នាក់គាត់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះ តា យឹម ហើយនឹងយាយ យន ចាស៕

កៈ
បាទហើយចឹងប្រសិនជាឪពុកហើយនឹងម្ដាយរបស់អ្នកមីងគាត់ទាំង២នាក់គាត់មានព្រះជន្មរស់នៅនឹងថាតើគាត់ទាំង២នាក់នឹងមានព្រះជន្មប៉ុន្មានឆ្នាំហើយទៅអ្នកមីង???

ខៈ ចាសហើយប្រសិនជាគាត់ទាំង២នាក់គាត់មានជីវិតរស់នៅនឹងប្រហែល ៩០ ឆ្នាំ ចាសហើយនៅពេលដែលគាត់បានស្លាប់នឹងគឺគាត់ចូលអាយ ៧០ ជាងហើយចាសហើយសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺគាត់អាយុ ៥០ឆ្នាំហើយចាសហើយសំរាបឪពុករបស់ខ្ញុំនឹងគឺគាត់ ៧៥ រឺក៏ ៧៤ឆ្នាំ អីនឹងចាសនឹងហើយនៅពេលដែលគាត់បានមកវិញហើយបានគាត់នឹងបានស្លាប់ចឹងហាសចាសហើយសំរាប់ផ្ទះរបស់ឪពុករបស់ខ្ញុំនឹងមាន៩ខ្នងនៅខាងកោះឧញ្ញាតីហាសហើយនៅកន្លែងនេះនឹងគឺគេបានហៅថាកោះតូចហាសចាសនឹងហើយសំរាប់ម៉ុំរបស់យើងនឹងគឺ

គេបានហៅថាភូមិកោះតូចហើយសំរាប់ខាងខ្ញុំនឹងគឺគេថាក្បាលកោះហាសចាសគឺគេហៅថាកោះឧញ្ញាតីចាស៕

ក៖
បាទហើយចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើសំរាប់ម្ដាយរបសអ្នកមីងគាត់បានស្លាប់ដោយសារអ្វីដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺគាត់បានស្លាប់ដោយតែគាត់នឹងឈឺហើយសំរាប់នៅក្នុងជំនាន់ពោលពតនឹងគឺគ្មាននាក់ណាធ្វើបាបគាត់នោះទេចាសហើយនឹងគឺនិយាយពីដើមមកគឺគាត់ឈឺហើយមកដល់ឪពុករបស់ខ្ញុំវិញទើបតែមកដល់វិញទេដែលគាត់បានស្លាប់ហាសហើយសំរាបឪពុករបស់ខ្ញុំនឹងគឺគាត់ធ្វើតែជាងកាប៉ាលជាងអីទាំងអស់នឹងហើយអ្វីក៏គាត់នឹងចេះដែលចាសនិយាយទៅគឺជាជាងទូតងរហើយនឹងទូតជារនិយាយរួចទៅគឺគាត់ចេះទាំងអស់ចាសបានគេនឹងបានឃាតអោយនៅកន្លែងនឹងហាសហើយប្រសិនជាអីនឹងគឺគាត់បានស្លាប់បាត់ហើយហើយសំរាប់បងរបស់ខ្ញុំដែលគាត់បានទៅបាត់ដំបងមួយនឹងគឺគាត់នៅនឹងហាសដោយសារគាត់ទៅតាមប្ដីរបស់គាត់ហាសហើយដល់ពេលនឹងគឺក៏គាត់នឹងបានស្លាប់នឹងកន្លែងនឹងតែម្ដងហាសហើយគាត់មានកូនចំនួន៣នាក់ហើយកូនស្រីរបស់គាត់នឹងមួយបានមកវិញហើយនឹងម្ដាយមានមួយហើយលូវនឹងម្ដាយរបស់គាត់នឹងបានស្លាបទៀតហើយលូវនឹងគឺនៅសល់តែកូនរបស់គាត់ហើយកូននឹងគឺគេមានប្ដីហើយមានកូនចំនួន
៥នាក់រឺក៏
៦នាកហើយសំរាប់អាប្រុសនឹងគឺគាត់គ្រោះថ្នាក់ចរាចរនឹងក៏បានស្លាប់ទៀតចាសហើយសំរាប់សព្វថ្ងៃនឹងគឺនៅតែប្រពន្ធហើយនឹងកូននឹងហាសចាសនឹងសំរាប់បងរបស់ខ្ញុំនឹងហាសនឹងហើយគឺគេបានជំលាស់ទៅបាត់ដំបងស្លាប់ប្ដីហើយនឹងប្រពន្ធហើយទៅគឺគេបានមកវិញនឹងតែម្នាក់ឯងនោះទេគឺនៅសល់តែកូនមួយនោះទេចាស៕

ក៖
បាទហើយហេតុអ្វីបានជានៅពេលដែលទៅបាត់ដំបងនឹងបានជាគាត់បានស្លាប់គឺគេបានយកពួកគាត់នឹងទៅសំរាប់រឺក៏យ៉ាងមិចដែលទៅអ្នកមីង???

ខ៖
ចាសនិយាយទៅគឺគាត់នឹងអត់បានហើយនឹងអត់ទឹកហាសចាសដោយសារគាត់នឹងបានទៅបូតស្រូវហាសហើយនៅពេលដែលគេបានឃើញគាត់ចឹងទៅគឺគេបានវៃគាត់ហើយនៅពេលដែលគេបានវៃគាត់ចឹងទៅគឺគាត់ក៏បានស្លាប់ចឹងទៅនិយាយទៅនៅពេលដែលគេបានវៃគាត់នឹងគឺគាត់មិនស្លាប់ភ្លែមនោះទេគឺគាត់ឈឺហាសហើយនៅពេលដែលឈឺយូរយូរទៅគាត់អត់បាយហើយនឹងអត់ទឹកទៀតក៏បានស្លាប់ចឹងទៅពីព្រោះអីនឹងគាត់អត់ពេកនឹងហើយរួចនៅពេលដែលគាត់បានបូតស្រូវហើយចឹងទៅគាត់បានយកវានឹងមកបុកហើយយកបុកនឹងក្បាលតូចតូចនឹងហាសហើយក៏បានហូបចឹងទៅពីព្រោះអីនឹងគឺគាត់អត់ពេកចឹង

ហាសចាសនិយាយទៅគឺវាបានយកទៅសំលាប់តែម្ដងហាសវាបានយកទៅអត់អោយយើងនឹងបានហូបបាយហាសនិយាយាទៅគឺបាត់ដំបងហើយនឹងមោងហើយបាត់ដំបងហើយនឹងខាងសៀមរាមនឹងហើយសំរាប់បងរបស់ខ្ញុំនឹងគឺគាត់រស់បានដោយសារគាត់នឹងបាននេរសាទត្រីហាសចាសបងស្រីរបស់ខ្ញុំគឺគាត់បានចេះជាវទូតហាសចាសដល់ពេលហើយចឹងទៅបានគេបានយកគាត់នឹងទៅខាងនេរសាទខាងជាវទូតហើយយកត្រីយកអីអោយចឹងទៅហាសចាសដល់ពេលហើយចឹងទៅបានកូននឹងបានរស់ចឹងទៅដែលគាត់បានរួចម្ដាយមួយនឹងចាសកុំអីនឹងគឺគាត់នឹងបានស្លាប់ទៀតបងរបស់ខ្ញុំនឹងហាសពីព្រោះអីនឹងគឺអស់រវីងហើយនឹងគឺគាត់គ្មានសំរាប់ហូបហើយសំរាប់ប្ដីរបស់គេនឹងបានទៅបូតស្រូវរបស់គេនឹងចាសហើយនៅពេលដែលគេបានបូតហើយយកមកចាសហើយនៅពេលដែលបានមកហើយចឹងគឺយកបុកបុកហើយចឹងគឺគេបានមកទាន់ហើយនៅពេលដែលគេបានទាន់ចឹងគឺគេបានចាប់យកទៅវៃហើយនៅពេលដែលគេបានវៃវៃហើយចឹងគាត់ក៏បានឈឺហើយនៅពេលដែលឈឺឈឺយូរយូរទៅគឺគាត់ក៏បានស្លាប់ហាសចាសហើយនិយាយទៅគឺគាត់គ្មានអ្វីនឹងហូបចឹងហាសហើយសំរាប់នៅខាងនោះវិញចាសនឹងសំរាប់នៅខាងបាត់ដំបងហើយនឹងនៅខាងសៀមរាបនឹងគឺខ្លាំងគឺគ្មានអ្វីសំរាប់ហូបចាសហើយសំរាប់ខ្ញុំខាងព្រះវិហារស្ងួតនឹងវាគ្រាន់តិចហាសក៏ប៉ុនតែនឹងសំរាប់បបរនឹងគឺវាពារក៏ខ្លូតហើយសំរាប់កាក់នឹងបានប្រហែលជាមួយក្ដាប់អីនឹងហាសចាសនិយាយទៅគឺមានសុទ្ធទឹកតែម្ដងហាសចាសនិយាយទៅមួយរឹកដែលខ្ញុំរៀបនឹងនៅពេលដែលខ្ញុំបានទៅយកទុងមកពីសហាករនឹងមកគឺគេបានអោយខ្ញុំនឹងរៀបហើយចឹងគឺសុទ្ធតែទឹកហើយចោលចឹងទៅហេហេហេហេហេសំរាប់កាល់នឹងហាសចាសហើយនិយាយទៅគឺសុទ្ធទឹកបបរហើយពេលចឹងទៅហើយមានអង្ករនឹងតែបន្តិចបន្តិចចឹងហាសហើយដូចថាសំរាប់មួយខ្ទះនឹងយើងដាក់១០កំប៉ុងហើយយើងមកដាក់៥កំប៉ុងវិញចឹងហាសចាសដល់ពេលចឹងគឺវារាយហើយគឺវាមិនខាប់នោះទេចាសហើយើសំរាប់ម្នាក់ម្នាក់នឹងគឺហៀលហើយសំរាប់ខ្ញុំនឹងក៏ហៀលដែលហាសចាសហើយគ្មានរបស់របបណាទិញហើយនឹងដូចណាគឺគ្មាននោះទេចាសហើយប្រសិនជាគេបានស្ទោរជំឡូរនឹងគឺជាជំឡូរឈើនឹងបិនបិននេះគឺគេបានអោយយើងនឹងស្ទុងស្រូវហាសចាសហើយគឺគេបានអោយនឹងទូរដូចជាបិនណោវនោះឯងចាសហើយគឺគេបានអោយយើងនឹងទៅទូរហើយច្រើនច្រើនណាស់ហើយទំរាំមបានមកដល់នឹងគឺយើងនឹងចង់បាក់ករហាសចាសនិយាយទៅគឺគ្មានស្រួលនោះទេហើយសំរាប់យើងនឹងគឺគេអោយយើងនឹងដើរទូរហាសហើយទូនឹងមានទៅជិតអីនិយាយទៅគឺទៅដល់ព្រះវិហារស្ងួតដែលនៅខាងកើតហាសនិយាយទៅគឺឆ្ងាយខ្លាំងណាស់ចាសហើយដល់ទៅផ្លូវព្រែកតាមែកហើយយើងបានមកខាងកើតទៀតចាសនឹងហើយ៥គីឡូនិយាយទៅគឺឆ្ងាយខ្លាំងណាស់រាប់រយគីឡូហាសចាសហើយយើងគិតមើលមើលយើងទូរតាំងពីម៉ោង៣រឺក៏ម៉ោង៤អីនឹងហើយនៅពេលដែលយើងបានចេញពីម៉ោង៤នឹងទៅរហូតដល់ម៉ោង១២អីនោះបានយើងនឹងបានទៅដល់ចាសហើយនៅពេលដែលគេបានមកដល់វិញហើយចឹងគឺគ្មាននាក់ណាដែលសប្បាយចិត្តនោះទេហើយសំរាប់អ្នកទាំងអស់នឹងគឺបបួលគ្នាហូបហើយចាសហើយសំរាប់អ្នកខ្លះនឹងក៏គេបានចាក់ទឹកចោលចឹងហើយសំរាប់អ្នក

ខ្លះទៀតនឹងក៏គេមិនបានហូបចឹងទៅចាសនិយាយទៅគឺគេចេះតែទៅហើយចាសដែលនៅជំនាន់នឹងហាសចាស៕

កៈ
បាទហើយចឹងនៅពេលដែលគេបានដាក់តែទឹកបបរសំរាប់អោយអ្នកមីងចឹងសំរាប់អ្នកមីងហូបមិនបានឆ្អែតនោះទេមែនដែលទេអ្នកមីង???

ខៈ
ចាសនិយាយទៅគឺខ្ញុំហូបមិនឆ្អែតនោះទេចាសពីព្រោះអីនឹងគឺសំរាប់បបរនឹងគឺគ្មានគោកអ្វីនោះទេគឺមានតែទឹកតែម្តងហាសចាសរួចហើយគឺយើងចេះតែហុតទឹកនឹងចឹងទៅហាសចាសហើយសំរាប់យើងនោមតែ២ដងនឹងគឺវាអស់ហើយចាសនិយាយទៅគឺគ្មានអ្វីនោះទេចាសហើយសំរាប់ខាងខ្ញុំនឹងគ្រាន់តែវានឹងគឺវាគ្រាន់តែថាវាពិបាក់នឹងលើកដីហើយនឹងលើកអីចឹងទៅហាសចាសហើយសំរាប់នៅក្នុងជំនាន់នឹងគឺយើងនៅក្មេងនឹងគឺយើងនឹងចេះតែសប្បាយចឹងទៅហាសចាសនិយាយទៅសប្បាយគ្រាន់តែថាយើងនឹងបានលើកដីហើយយើងបានប្រណាំងគ្នាចឹងហាសចាសហើយយើងបានប្រឡាយហើយសំរាប់ប្រឡាយនឹងគឺវាធំធំខ្លាំងណាស់ណាហើយសំរាប់និយាយទៅគឺនៅទីនោះហាសចាសគឺពីទឹកន្លែងនឹងទៅដល់សរសេដល់ប្រឡាយនោះចាសហើយសំរាប់ប្រឡាយនឹងគឺយយើងនឹងបានលើកនឹងគឺវាមានជំរៅជ្រៅខ្លាំងណាស់ណាស់ណាចាសហើយសំរាប់ប្រឡាយនឹងគឺយើងទាំងអស់គ្នានឹងបានធ្វើកាំជណ្តើលនឹងដើម្បីឡើងចឹងហាសចាសហើយសំរាប់ជំរៅនឹងគឺវានៅពេលដែលយើងបានឡើងនឹងទុំរាំមតែយើងនឹងបានឡើងមកលើនេះអីនឹងរួចហើយសំរាប់ខ្នងនឹងលើនឹងគឺមានវាប្រវែង៧ម៉ែត្រទៅដល់១០ម៉ែត្រហាសចាសនឹងសំរាប់ខ្នងដែលនៅខាងលើនឹងហាសចាសនិយាយទៅគឺវាធំខ្លាំងណាស់ណាពីព្រោះអីនឹងគឺជំរៅនឹងគឺវាមានទំហំធំហាសនិយាយទៅគឺគេមានអោយយើងនឹងទៅកំពុងចំលងហើយគឺគេបានស្នើអោយកងចល័តអោយទៅកំពុងចំលងហើយដល់ពេលហើយចឹងទៅគឺគេចង់រកសំលាប់យើងនឹងចោលចឹងហាសចាសដែលគាត់នឹងគឺជាកងចល័តនឹងហាសចាសរួចហើយគឺពួកគេមានបានចល័តទាន់អីនឹងគឺពេលនឹងវាបាក់ផ្ទះចឹងទៅហាសចាសហើយនៅពេលដែលបាក់ផ្ទះចឹងទៅគឺពួកវានឹងបានភ័យហើយពួកវានឹងក៏បានរត់ទៅចោលគ្នាអស់ចឹងទៅសំរាប់នៅក្នុងជំនាន់នឹងគឺគេបានចង់សំលាប់ចោលសំរាប់កងចល័តហើយពួកគេបានលើកថ្មហើយនឹងបានដាក់ទុបហើយនឹងបានបិតនឹងសំរាប់ទន្លេរតូចរបស់គេចឹងហាសចាសហើយសំរាប់ទន្លេរនឹងគឺនៅខាងកើតនឹងហាសហើយសំរាប់ទៅព្រះវិហារសួត៍នឹងគឺវាឆ្ងាយហើយដល់ពេលដែលអ្នកដែលនៅខាងកើតនឹងគឺគេបាននៅឆ្ងាយចឹងគឺគេបានយកមកដូចជាកងពិសេសចឹងហាសចាសនិយាយទៅគឺកងពិសេសនឹងគឺកំលាំងរបស់គេនឹងខ្លាំងខ្លាំងនឹងហាសចាសហេហេហេហេនិយាយទៅគឺទាំងស្រីហើយនឹងទាំងប្រុសនឹងគឺគេបានមកទឹកន្លែងនឹងហាសចាសហើយនៅពេលដែលគេបានយកមកហើយចឹងគឺគេមិនបានអោយគេនឹងបានជីកដីនោះទេស្រាប់តែពេលនឹងគឺពួកគេនឹងគឺជីកដីហើយនឹងលីថ្មហើយនឹងបានចាក់ទៅទន្លេរនឹងតែម្តងហើយនៅពេលដែលគេបានចាក់នឹងគឺគេបានចាក់ប្រដេញប្រដេញដើម្បីបិទទន្លេរតូចរបស់គេ

ចឹងហាសចាសនិយាយទៅគឺគេចង់ធ្វើដូចជាស្ពានហាសហើយនៅពេលនឹងគឺមិនទាន់បានណាគឺផ្ទះរបស់គឺនឹងបានបាក់ផ្ទះហើយនឹងពួកគេនឹងចង់សំលាប់កងចល័តនឹងចោលចាសគឺគេចង់សំលាប់កងចល័តនឹងហាសចាសហើយសំរាប់នៅក្នុងជំនាន់របស់ខ្ញុំនឹងគឺគេបានចង់យកអ្នកដែលបានធ្វើការងារទេព្យនឹងយកទៅសំលាប់ហើយនៅពេលដែលគេបាននិយាយទៅយកយើងនឹងទៅធ្វើការងារជាទេព្យនឹងគឺគេបែបជាយកយើងនឹងទៅសំលាប់ចោលនោះទេចាសនឹងគឺនៅក្នុងជំនាន់របស់ខ្ញុំហើយសំរាប់ខ្ញុំនឹងគឺខ្ញុំមានមិត្តភក្តិម្នាក់នឹងគឺគេបានយកគាត់នឹងទៅសំលាប់ចោលដែលនឹងហាសចាសហើយគឺគេបានយកទៅធ្វើការងារពេទ្យចឹងហាសហើយគេបាននិយាយថាសំរាប់មិត្តនារីម្នាក់នេះគឺត្រូវទៅធ្វើការងារពេទ្យហើយទៅធ្វើការងារនឹងនៅកន្លែងនេះចឹងចឹងហាសចាសហើយដល់ពេលគេនិយាយហើយចឹងទៅគឺគេបានយកទៅសំលាប់ចោលចឹងទៅហើយដល់ពេលដែលចប់ហើយចឹងក៏យើងមិនបានឃើញគេមកដែលចឹងហាសចាសសំរាប់នៅក្នុងជំនាន់នឹងគឺវាយ៉ាប់ខ្លាំងណាស់ណាហើយប្រសិនជាយើងនឹងនិយាយមិនស្រួលនឹងគឺគេនឹងយកយើងនឹងទៅសំលាប់ចោលហើយចាសហើយគឺគេវៃចោលនៅកន្លែងនឹងក៏មានដែលចឹងហាសចាសរួចហើយនៅពេលដែលពួកគេបានទៅបាត់ទៅបាត់ហើយចឹងហើយពេលនឹងគឺយើងបានសួរគេសួរឯងនឹងគឺគ្មាននាក់នឹងដឹងនឹងនោះទេចាសគឺគ្មាននាក់ដឹងទៅកន្លែងណានោះទេចាសសំរាប់នៅក្នុងជំនាន់នឹងចាសហើយសំរាប់មិត្តភក្តិរបស់ខ្ញុំនឹងគាត់នៅពេលដែលមានអ្វីហូបតែបន្តិចនឹងក៏គាត់នឹងបានចែកគ្នាហូបដែលហាសចាសដល់ពេលដែលគេបានយកទៅធ្វើការងារពេទ្យហើយចឹងគឺគ្មាននាក់ណាបានដឹងនោះទេហើយគាត់ក៏មិនបានមកវិញដែលចាសហើយរហូតដល់ចប់នឹងក៏គ្មាននាក់ណាដឹងដែលថាគាត់មិនបានដឹងដែលចាសគឺគេបានសំលាប់គាត់ហើយចាសហើយពួកគេបានប្រាប់ថាយកគ្នាទៅធ្វើការងារពេទ្យនិយាយទៅគឺគេបានកហុសគ្នាហើយធ្វើការងារពេទ្យធ្វើការងារពេទ្យមានណាគឺគេបានយកទៅសំលាប់ចោលនិយាយទៅគឺពួកវានឹងបានកហុសយើងចឹងហាសហើយពួកវានឹងបានសំលាប់គាត់នឹងចោលហើយសំរាប់ភូមិណាមួយនឹងគឺគេបានអូសទាំងខ្សែទាំងខ្សែចឹងហើយគេបានដាក់ក្បាលនឹងដងចបនឹងលឺសូផូសផូសហើយនៅពេលដែលគេបានវៃនឹងគឺថាគេបានអោយយើងនឹងបានអង្គុយចុះហើយទាំងខ្សែនឹងគឺគេបានវៃយើងនឹងចោលហើយលឺសូរតែផូសផូសចឹងហាសចាសហើយនិយាយទៅគឺខ្ញុំគ្រាន់តែខ្ញុំនឹងបានលឺគេនិយាយទេណាពីព្រោះអីនឹងគឺខ្ញុំនឹងមិនដែលបានឃើញផ្ទាល់នឹងភ្នែកនោះទេចាសហើយគ្រាន់តែឃើញហើយនឹងបានឃើញគេចាប់ទៅចាប់ទៅចឹងទៅហើយនៅពេលដែលគេបានអោយយើងទៅចឹងទៅគឺគេនិយាយថាអោយយើងនឹងទៅធ្វើការងារជាពេទ្យក៏ប៉ុនតែនឹងគឺគេបាននិយាយកកហុសយើងនឹងហើយគេបានយកយើងនឹងទៅសំលាប់យើងចោលចឹងហាសចាសហើយគឺខ្ញុំបានលឺចឹងមែនហើយប្រសិនជាអោយខ្ញុំនឹងបានឃើញនឹងភ្នែករបស់ខ្ញុំនឹងគឺខ្ញុំមិនបានឃើញនោះទេចាសហើយនឹងនៅពេលដែលបានឃើញនឹងបានវៃដោយផ្ទាលនឹងគឺខ្ញុំមិនបានឃើញនោះទេចាសនិយាយទៅគឺនៅក្នុងជំនាន់នឹងគឺវាយ៉ាប់ខ្លាំងណាស់ចាស៕

កៈ
បាទហើយចឹងខ្ញុំអរគុណច្រើនអ្នកមីងហើយចឹងសួរបកក្រោយតិចអ្នកមីងថាតើនៅពេលដែលគេបានយកកងចល័តនឹងយកទៅសំលាប់នឹងក៏ប៉ុនតែនឹងគឺគេបានយកយើងនឹងទៅលីថ្មហើយនឹងលីអីចឹងទៅថាតើគេមានបានយកអ្នកមីងទៅជាមួយនឹងគេដែលរឺទេអ្នកមីង???

ខៈ
ចាសសំរាប់ខ្ញុំនឹងគឺថានៅក្នុងជំនាន់នឹងគឺគេបានហៅខ្ញុំថាគឺជាកងពិសេសពិសេសតែម្តងនឹងសំរាប់ជំនាន់នឹងគឺគេបានហៅតែអ្នកដែលពិសេសពិសេសនោះទេហើយនឹងអ្នកដែលខ្លាំងខ្លាំងទៅនិយាយទៅដូចថានៅក្នុងចំនួនមនុស្ស ១០០០ នាក់ចឹងគឺគេយកតែត្រឹមតែ ៥០០ នាក់នោះទេចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំមិនចំហើយកាល់នឹងប្រសិនជាចំខ្ញុំទៅនឹងហើយនៅពេលដែលគេបានទៅបានតែ ១
យប់នឹងគឺយើងបានលឺដំណឹងចឹងមកហេហេហេហេហើយមកវិញអស់ចឹងទៅចាសហើយយើងមានបានលើកអីណាពីព្រោះអីនឹងយើងបានលឺដំណឹងថាគេចង់សំលាប់ចោលចឹងហាសហើយយើងក៏បានបកមកវិញហើយគ្មានបានលីអ្វីនោះទេចាស៕

កៈ
បាទហើយចឹងនៅក្នុងជំនាន់នឹងអ្នកមីងគឺជាកងចល័តពិសេសមែនដែលទេអ្នកមីងហើយចឹងអ្នកមីងឡូយមែនទែនអ្នកមីងហេហេហេ???

ខៈ
ចាសសំរាប់ខ្ញុំនិយាយទៅនៅក្នុងជំនាន់នឹងគឺខ្ញុំមានមាឌកាម៉ាបហាសនឹងហើយសំរាប់អាយុទើបតែ១៨ឆ្នាំរឺក៏១៥ឆ្នាំដូចមីកូនរបស់ខ្ញុំនឹងដែលគាត់បានទៅមិញនឹងដែលគាត់ពាក់អាវក្របាមមុននឹងនឹងគឺជាកូនពៅរបស់ខ្ញុំដែលគាត់បានទៅមិញនឹងហាសចាសនឹងសំរាប់ខ្ញុំនឹងគឺខ្ញុំចឹងហាសគឺមានមាឌចឹងចាសហើយសំរាប់ខ្ញុំ១៥ឆ្នាំនឹងគឺបិនកូនរបស់ខ្ញុំនឹងចាសហើយយើងមានសាច់ហើយយើងបានចល័តចឹងហាសចាសនិយាយទៅគឺនៅក្នុងជំនាន់នឹងគឺខ្ញុំមានកំលាំងណាស់ហើយក៏មិនសូវជាឈឺដូចគេណាហើយសំរាប់ថៅរបស់ខ្ញុំដែលគាត់បានដើរទៅមុននឹងគឺគាត់នឹងសាច់ដែលហើយសំរាប់សាច់នឹងគឺឡើងកាម៉ាបកាម៉ាបនឹង១៥ឆ្នាំហាសហើយសំរាប់ខ្ញុំកាល់ខ្ញុំ១៥ឆ្នាំនឹងគឺខ្ញុំមានវ័យស្រករគ្នានឹងហាសនិយាយទៅគឺពេញសាច់តែម្តងហាសចាសហើយសំរាប់មកដល់លូវនឹងគឺខ្ញុំឈឺជើងពីព្រោះអីនឹងគឺមកពីខ្ញុំនឹងប្រឹងពេកហាសចាស៕

កៈ
បាទហើយចឹងអរគុណច្រើនអ្នកមីងហើយចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើសំរាប់អ្នកមីងមានដឹងទេថានៅក្នុងជំនាន់ណាដែលគេបានចូលមកជួយរំដោះប្រជាជនខ្មែររបស់យើងហាសអ្នកមីងហើយសំរាប់អ្នកមីងមានដឹងថានៅក្នុងជំនាន់ណាដែលរឺកីឆ្នាំណាដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺខ្ញុំមិនដឹងជាឆ្នាំប៉ុន្មាននោះទេដែលនៅក្នុងជំនាន់រំដោះនឹងហាសចាសសំរាប់ខ្ញុំគឺខ្ញុំមិនជាសូវបានចាំដែលចឹងហាសចាសហើយប្រសិនជាបានឪគាត់បាននៅនឹងបានបានគាត់បានដឹងហើយសំរាប់រំដោះនឹងគឺយួនបានចូលនឹងមែនដែលទេនឹងហើយគឺសំរាប់ខ្ញុំមិនបានចាំនៅកន្លែងនឹងដែលនិយាយទៅគឺមិនបានដឹងថាឆ្នាំអ្វីនោះទេហោមីងអូនមីងអូនឯងមានដឹងថាពេលដែលគេបានរំដោះនឹងនៅឆ្នាំណាដែលរឺទេអត់បានដឹងថាគេបាននិយាយថាយួននឹងបានចូលមករំដោះទឹកដីនឹងនៅឆ្នាំណាឆ្នាំដែលរឺទេមែនដែលទេអត់ដែលបានលឺពូមីងអីគាត់និយាយទេមែនដែលទេចាសនិយាយទៅគឺអត់បានចាំនោះទេហោហោហោហោចាស៕

ក៖
បាទហើយចឹងនៅពេលដែលគេបានចូលមករំដោះប្រជាជនខ្មែរនឹងសំរាប់អ្នកមីងបានរស់នៅទីកន្លែងណាដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនឹងនៅពេលដែលគេបានមករំដោះមកនឹងសំរាប់មុនដំបូងនឹងគឺខ្ញុំបានរស់នៅព្រះហារសួត់ចាសគឺខ្ញុំបានរស់នៅខាងព្រៃកចាស់ដល់ពេលហើយចឹងដល់ពេលចប់ហើយចឹងគឺខ្ញុំបានមករស់នៅផ្ទះរបស់ខ្ញុំវិញមកគឺជាកោះឧញ្ញាតីនឹងហាសចាសមកភូមិស្រុកនឹងវិញទៅចាសនឹងហើយសំរាប់រៀបចំអីហើយចឹងនៅពេលដែលបានរៀបចំអីចឹងទៅដែលបានមកពីជំនាន់ពោលពតនឹងហាសដល់ពេលហើយចឹងទៅចប់ហើយចឹងទៅគឺយើងទាំងអស់គ្នានឹងបានមកស្រុកភូមិវិញហាសចាសគឺបិនហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានមកភូមិស្រុកកំកើតរបស់អ្នកមីងហើយចឹងថាតើអ្នកមីងមកជាមួយនឹងក្រុមគ្រួសាររបស់អ្នកមីងរឺក៏មកម្នាក់ឯងដែលទៅអ្នកមីង???

ខ៖
ចាសនៅពេលដែលខ្ញុំបានមកវិញជំនាន់ពោលពតនឹងគឺខ្ញុំបានមកជាមួយនឹងឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងហាសចាសហើយសំរាប់បងប្អូនរបស់ខ្ញុំមានប៉ុន្មាននាក់គឺមកទាំងអស់គ្នានឹងហាសចាសហើយនៅពេលដែលមកវិញចឹងទៅហើយនឹងមកពីបាត់ដំបងហើយនឹងសំរាប់អ្នកណាដែលរស់រស់នឹងគឺបានមកនៅភូមិស្រុករបស់ខ្ញុំនឹងទាំងអស់នឹងហាសហើយសំរាប់អ្នកខ្លះដែលពួកគាត់អត់មានផ្ទះនៅចឹងហាសហើយគឺមកនៅជុំផ្ទះរបស់ខ្ញុំទាំងអស់ពីព្រោះអីនឹងផ្ទះរបស់ឪពុកខ្ញុំនឹងមាន៣រឺក៏៤ខ្នងហាសនិយាយទៅគឺធំជាងផ្ទះនេះទៅទៀតហាសដល់ពេលចឹងហើយសំរាបប្អូនប្អូនរបស់ខ្ញុំអីនឹងហើយបានមកហើយសំរាប់អ្នកខ្លះអីនឹងគេឆេះផ្ទះអីនឹងគឺគេគ្មានផ្ទះអីនឹងហាសគឺមកនៅជាមួយគ្នាចាសហើយនៅពេលអ្នកខ្លះនឹងគឺគេបានប្ដីហើយនឹងប្រពន្ធអីនឹងបានគេបានបែកដោយខ្លួនចឹងទៅទំរាមមានលុយកាក់អីនឹងធ្វើផ្ទះចឹងហាសហើយដល់ពេលចឹងហើយបានរស់នៅជាមួយនឹងគ្នាចឹងទៅហើយសំរា

ប់ផ្ទះរបស់ឪពុកខ្ញុំនឹងគឺគាត់បានយកមកបងប្អូនរបស់ខ្ញុំនឹងតែ២នាក់នោះទេហើយយើងបានលក់ដូរចឹងទៅហើយយើងក៏បានមកធ្វើផ្ទះនឹងចឹងនៅជាមួយគ្នាចឹងទៅហើយសំរាប់បងស្រីរបស់ខ្ញុំនឹងពាក់កណ្តាល់ហើយនឹងខ្ញុំពាក់កណ្តាលចឹងហាសចាសហើយសំរាប់ខ្ញុំនឹងបានខ្វះលុយប៉ុន្មានគឺខ្ញុំបានទិញហើយដាក់វាបញ្ចូលចឹងទៅគឺយើងបានទិញបញ្ចូលចឹងទៅហាសចាសនឹងហើយ៕

កៈ
បាទហើយចឹងដែលអ្នកមីងបានដើរហើយបែកនៅក្នុងជំនាន់ពោលពតនឹងហើយបានដើរជាមួយនឹងឪពុកហើយនឹងម្តាយរបស់អ្នកមីងចឹងថាតើតាមផ្លូវនឹងតើអ្នកមីងបានជួបនឹងពួកពោលពតទៀតដែលរឺទេនៅពេលដែលអ្នកមីងបានមកស្រុកកំណើតវិញហាស៕

ខៈ
ចាសនៅពេលដែលខ្ញុំបានមកស្រុកកំណើតរបស់ខ្ញុំវិញនឹងគឺមិនបានឃើញពួកពោលពតនោះទេនិយាយទៅគឺខ្ញុំបានឃើញតែទាហ៊ានហើយទាហ៊ាននឹងគឺជាទាហ៊ានជនជាតិវៀតណាមហាសចាសនិយាយទៅគឺមិនបានឃើញទាហ៊ានពួកពោលពតនឹងនោះទេគ្រាន់តែបានឃើញទាហ៊ានជនជាតិវៀតណាមចាស៕

កៈ
បាទហើយចឹងសំរាប់ពួកទាហ៊ានពួកពោលពតនឹងថាតើពួកគេបានរត់ទៅណាអស់ហើយទៅអ្នកមីង???

ខៈ
ចាសសំរាប់ពួកទាហ៊ានពួកពោលពតនឹងគឺខ្ញុំមិនបានដឹងថាពួកគេបានរត់ទៅណាដែលចឹងហាសប្រហែលជាពួកពោលពតនឹងបានរត់ចូលទៅក្នុងព្រៃអីចឹងទៅហាសចាសហើយសំរាប់ពួកវានឹងគឺមិនបាននៅតាមភូមិនោះទេចាស៕

កៈ
បាទហើយចឹងនៅពេលដែលអ្នកមីងបានដើរតាមផ្លូវនឹងអ្នកមីងបានឃើញពួកទាហ៊ានពោលពតនឹងរឺក៏ជាទាហ៊ានជនជាតិវៀតណាមនឹងថាតើពួកវានឹងបានធ្វើបាបអ្នកមីងដែលរឺទេអ្នកមីង???

ខៈ
ចាសនៅពេលដែលខ្ញុំនឹងបានដើរមកវិញចឹងគឺពួកគេនឹងមិនបានធ្វើបាបខ្ញុំនោះទេចាសហើយនៅពេលដែលខ្ញុំបានដើរមកចឹងគឺខ្ញុំគ្មានបានអ្វីនោះទេហើយក៏គ្មានអ្វីបានហូបដែលហាសចាសហើយអ្វីក៏គ្មានជិះដែលចាសហើយយើងបានរ៉ែកខោអាវរ៉ែកមកចឹងទៅហើយយើងគ្មានអ្វីនឹងជិះនោះទេសំរាប់ពេលដំបូងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានមកចឹងហើយដើរដើរចឹងដើររយះពេលប៉ុន្មានថ្ងៃនឹងបានមកកដល់ដែលអ្នកមីង???

ខ៖
ចាសនិយាយទៅគឺខ្ញុំដើរនឹងប្រើរយះពេល២ថ្ងៃរឺក៏៣ថ្ងៃនឹងគឺដល់ហើយពីព្រោះអីនឹងយើងបានដើរមកពីព្រះហារស្ទួត័នឹងមកចឹងហាសចាសហើយសំរាប់ផ្លូវនឹងគឺវាតូចហាសហើយពីព្រោះអីនឹងគឺយើងបានដើរផ្លូវកាត់ហាសចាសនឹងហើយ៕

ក៖ បាទហើយចឹងសំរាប់អ្នកមីងដើរតែ១ថ្ងៃទេមែនដែលទេអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំបានដើរតែ១ថ្ងៃនោះទេតែសំរាប់បងរបស់ខ្ញនឹងគឺគាត់បានដើរអស់រយះពេល៦ថ្ងៃរឺក៏៧ថ្ងៃបានទៅដល់ហាសចាសគឺគាត់បានដើរពីបាត់ដំបងមកហាសហើយនៅពេលដែលយើងបានទៅដល់ណាគឺយើងដេកនៅទីកន្លែងនឹងដើរទៅដល់កន្លែងណាគឺយើងដេកនឹងកន្លែងនឹងហាសចាសនឹងសំរាប់ខាងនឹងហើយយើងនឹងក៏គ្មានអ្វីជិះដែលចឹងហាសគឺយើងមានតែរទេះហើយនឹងដាក់កងចឹងហាសហើយនឹងដាក់ខោអាវហើយនឹងចានហើយនឹងឆ្នាំងអីចឹងទៅពីព្រោះអីនឹងសំរាប់ខាងខ្ញុំគឺគ្មានអ្វីនឹងជិះនោះទេគឺមានតែរ៉ែកហើយនឹងទូរ៉ែកហើយនឹងទូហេហេហេហេចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានដើរមកអស់រយះពេល១ថ្ងៃនឹងថាតើមកដល់ស្រុកកំណើតវិញនឹងថាតើមានអ្នកណាដែលបានមកផ្គត់ផ្គង់នឹងសំរាប់ចិញ្ចឹមអ្នកមីងដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនឹងគឺមានតែខ្ញុំនឹងពីព្រោះអីនឹងសំរាប់ខ្ញុំនឹងគឺគ្មានឪពុកហើយនឹងម្ដាយមកពីណាគឺមានតែបងស្រីរបស់ខ្ញុំនឹងគឺហើយសំរាប់ងរបស់ខ្ញុំនឹងហើយកាល់ដែលបងរបស់ខ្ញុំនឹងគឺគាត់មិនទាន់បានមកដល់នឹងគឺមានតែខ្ញុំនឹងធ្វើចឹងទៅរួចពេលហើយចឹងទៅគឺមានឪពុកហើយនឹងខ្ញុំចឹងទៅគឺយើងធ្វើរហូតហើយសំរាប់ប្ដីរបស់ខ្ញុំនឹងគឺខាងធ្វើម្ហូបអីចឹងទៅហើយគាត់ធ្វើម្ហូបចឹងទៅនឹងសំរាប់ប្ដីរបស់ខ្ញុំនឹងហាសចាសហើយនៅពេលដែលនឹងគឺគេបានហៅគាត់នឹងមេជាងនឹងហាសគឺគេហៅគាត់ជាងម៉ៅហាសដែលជាដែកផ្សារហើយសំរាប់មុនដំបូងនឹងគឺយើងនឹងគ្មានទូតដរនោះទេហើយយើងមានតែទូតជារនឹងហាសហើយសំរាប់ទូតជារនឹងចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងដើរមកចឹងហើយសំរាប់អ្នកមីងបានម្ហូបពីណាដើម្បីសំរាប់ហូបចឹងទៅអ្នកមីង???

ខ៖
ចាសសំរាប់ពេលនឹងនៅពេលដែលខ្ញុំមកដំបូងនឹងគឺយើងមិនបានទិញត្រីនោះទេពីព្រោះអីនឹងកន្លែងគឺគេបានទៅបង់ត្រីនឹងហាសហើយយើងទៅរកទៅអីចឹងទៅមាននៅពេលដែលយើងបានលឺតាមមានម្ហូបអីនឹងគឺយើងនឹងទៅរកចឹងទៅនិយាយទៅគឺមិនសូវបានទិញគេនោះទេចាសហើយសំរាប់មកដំបូងមកដំបូងនឹងគឺថាត្រីនឹងគឺគេបានហៅថាបឹងគេចបឹងធំរបស់គេនឹងនិយាយទៅគឺសំបូរខ្លាំងណាស់ទាំងមានលាស់ធំអីនឹងគឺសំបូរខ្លាំងណាស់ចាសហើយសំរាប់ត្រីក្រុត្រប់នឹងគឺធំធំខ្លាំងណាស់គឺវាមិនបានទៅយកនោះទេនឹងហើយសំរាប់បឹងនឹងគឺខ្ញុំធំណាស់ហើយនៅពេលដែលយើងបានរកចឹងនៅពេលដែលយើងបានទៅរកជាមួយឪពុកហើយនឹងម្តាយគឺចឹងហាសហើយសំរាប់មួយថ្ងៃមួយថ្ងៃគឺគ្មានធ្វើអ្វីនោះទេចាសហើយសំរាប់ពីនឹងក៏យើងបានធ្វើការងារចំការអីតិចតិចនឹងគឺយើងបានធ្វើការនៅនឹងតែចាសហើយនៅពេលដែលយើងធ្វើការងារនឹងយើងចេះតែធ្វើម្ហូបអីចឹងទៅចាសហើយសំរាប់ប្តីរបស់ខ្ញុំនឹងគឺអោយតែគេនឹងបានបបួលទៅរកត្រីនឹងគឺគាត់ទៅហើយចាសទោះទៅដល់បាក់ខែងក៏គាត់ទៅដែលចាសហើយសំរាប់កាល់នឹងសំរាប់បាក់ខែងនឹងគឺសំបូងបឹងខ្លាំងណាស់ណាចាសហើយនៅពេលដែលគាត់បានទៅរកត្រីចឹងយើងតែងតែដាំបាយអោយគាត់ទៅតាមជាមួយចឹងទៅហាសចាសហើយនៅពេលដែលគាត់បានទៅរកចឹងគឺគាត់បានត្រីចឹងគឺគាត់បានអាំងត្រីអីនៅនឹងចឹងទៅហើយសំរាប់ត្រីមួយត្រីមួយនឹងគឺធំធំណាស់ហើយនៅពេលដែលគាត់រកបានចឹងយើងតែងតែទុក្ខសំរាប់ហូបចឹងទៅគឺយើងមិនបានដែលបានលក់នោះទេពីព្រោះអីនឹងគឺគេបានទៅរកគ្រាប់គ្នាចឹងហាសហើយសំរាប់មួយភូមិចឹងគឺមានចំនួន ២០
នាក់អីចឹងនឹងហាសដែលគាត់ទៅរកត្រីហាសចាសគឺទៅរកត្រីនឹងហាសនឹងហើយរួចនៅពេលដែលទៅរកនឹងគឺរកបានត្រីសុទ្ធតែល្អល្អណាស់មានសុទ្ធតែត្រីរសហើយនឹងត្រីដៀបអីនឹងហើយនឹងត្រីក្រាញ់ហើយនឹងត្រីក្រុត្រប់អីនឹងហើយនិយាយទៅគឺធំធំណាស់ចាសហើយសំរាប់ជំនាន់ពោលពតនឹងគឺមិនខ្វះនោះទេសំរាប់ត្រីនៅក្នុងជំនាន់នឹងហាសចាសហើយនៅពេលដែលបានត្រីនឹងគឺគេសុទ្ធដឹករទេះគោចាសនឹងហើយសំរាប់ជំនាន់ពោលពតនឹងគឺសំបូរត្រីខ្លាំងណាស់ហើយពេលនឹងគឺគេបានមិនអោយស៊ីនោះទេគ្រាន់តែគេបានដាក់ត្រីនឹងសំរាប់មួយឆ្នាំចឹងត្រីចំនួន
១០ត្រីអីចឹងទៅហើយនិយាយទៅគឺវាសំបូរហើយមិនដឹងជាវានឹងយកទៅណាវានោះទេចាសហើយពួកវានឹងបានធ្វើជាត្រីងៀតហើយនឹងត្រីដៀបះអីនឹងហាសចាសហើយពួកគេបានដាក់ត្រីនឹងមួយពេញមួយពេញនៅលើរទេះគោនឹងហាសចាសនឹងសំរាប់ជំនាន់ពោលពតនឹងហើយយើងមិនបានដឹងថាវាយកត្រីទាំងអស់នឹងទៅណានោះទេចាសនិយាយទៅគឺពួកវានឹងមិនបានអោយនឹងហូបតែងម្តងហាសចាសហើយមួយទៀតពួកវានឹងចង់សំលាប់យើងចោលហាសចាសនឹងហើយ៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងទៅរកត្រីនឹងនៅខាងព្រៃកលាភនឹងហើយសំរាប់អ្នកមី

ងបានរត់គេចហើយចឹងសំរាប់អ្នកមីងក្នុងមួយថ្ងៃនឹងថាតើអ្នកមីងរកបានត្រីនឹងចំនួនប៉ុន្មានគីឡូរដែលទៅអ្នកមីងហើយប្រសិនគិតជាគីឡូរហាសអ្នកមីង???

ខ៖

ចាសប្រសិនជាគិតជាគីឡូរទៅគឺខ្ញុំនឹងរកបានច្រើនខ្លាំងណាស់ប្រសិនជា១០គីឡូរអីនឹងហាសនឹងក្នុងមួយថ្ងៃនឹងហាសហើយសំរាប់ថ្ងៃណាទៅយើងបានហ៊ុនគ្នាចឹងទៅ៤នាក់រឺក៏៥នាក់អីចឹងទៅគឺយើងបានចែកគ្នាម្នាក់៤រឺក៏១០គីឡូរអីចឹងទៅហាសចាសហើយសំរាប់មួយថ្ងៃមួយថ្ងៃនឹងគឺយើងបានយកមកហើយយើងបានវះងៀតហើយដាក់វាហាអីចឹងទៅដើម្បីទុកហូបចឹងទៅចាសហើយសំរាប់លាសអីនឹងសំរាប់កាល់នឹងគឺនៅដងកាល់នៅឡើយនឹងហាសដូចថាសំរាប់ជារទូតនឹងគឺទៅយកអង្ករនឹងហាសហើយសំរាប់ខ្ញុំនឹងជាប់ដំបូងនឹងគឺខ្ញុំនឹងបានទៅយកក្រណាត់ហើយនឹងទៅយកទៅប្តូរទៅជាអង្ករហាសនឹងនៅខាងគីឡូរលេខ៧ហាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំបានទូរហាសហើយនិយាយទៅគឺខ្ញុំឆ្អែតឆ្អនអស់ហើយហើយនៅពេលដែលយើងបានមកហើយចឹងគឺដូចថាយើងមិនបានស្រណុកអីនឹងគឺគ្មាននោះទេយើងនៅតែពិបាក់ទៀតហាសចាសហើយសំរាប់យើងយើងគ្មានអង្ករអីនឹងគឺយើងបានទៅប្តូរទៅអ្នកស្រែហាសហើយនៅពេលដែលយើងបានដាំបានចេកពងមាន់នឹងក៏យើងបានយកចេកទាំងអស់នឹងទៅប្តូរទៅជាអង្ករដែលហើយយើងដើរទូរហាសចាសហើយទំរាមតែយើងនឹងបានជាអង្ករនឹងបានមកហាសហើយសំរាប់កូនរបស់ខ្ញុំនឹងគឺពួកវានឹងនៅតូចតូចហើយពួកវានឹងជួយទូរខ្ញុំចឹងទៅហើយសំរាប់ចេកពងមាន់ហើយនឹងចេកណាំវ៉ាអីនឹងគឺគ្មានអីបានច្រើនជាងនឹងនោះទេចាសហើយក៏គ្មានដឹងដែលហាសចាសហើយមិដូចជាលូវនឹងនោះទេមានម៉ូតូហើយគឺយើងបានទូរចង់ក្រិចកករយើងអស់ហើយពីព្រោះអីនឹងនៅពេលដែលយើងបានជួបនៅទីកន្លែងណានឹងគឺយើងទូរនៅកន្លែងនឹងហើយចប់ម៉ងហាសហើយសំរាប់ខ្ញុំនឹងគឺវេទនាដែលកាល់នៅក្នុងជំនាន់នឹងហើយសំរាប់បងថ្លៃរបស់ខ្ញុំនឹងក៏គាត់បានមករកហើយនឹងធ្វើការងារដើម្បីប្តូរយកអង្ករដែលហាសចាសនិយាយទៅគឺប្តូរអង្កររហូតដល់បែកចានហាសហើយគាត់បានដើរឆ្ងាយឆ្ងាយហើយនៅខាស្រែស្រែហាសពីព្រោះអីនឹងសំរាប់គេដែលនៅខាងស្រុកស្រែនឹងគឺគេសំបូរអង្ករហើយនឹងបានប្តូរអង្ករចឹងហាសចាស៕

ក៖

បាទហើចឹងនៅពេលដែលអ្នកមីងបានប្តូរជាម្ហូបហើយនឹងអង្ករហើយចឹងសំរាប់ក្រុមគ្រួសាររបស់អ្នកមីងត្រូវបានគ្រាប់គ្រងដោយសារអ្នកមីងមែនហើយនឹងបានហូបបានគ្រាប់គ្រាន់មានដែលទេអ្នកមីង???

ខ៖

ចាសសំរាប់ជំនាន់នឹងគឺខ្ញុំបានហូបបានគ្រាប់គ្រាន់ចាសនឹងហើយនៅពេលដែលបានចប់នឹងហើយបានហូបគ្រាប់គ្រាន់ហាសចាសហើយនឹងសំបូរម្ហូបសំរាប់ហូបនឹងហាសចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងខំប្រឹងនឹងរកដោយខ្លួនឯងចឹងហាសហើយនឹងបានចែកអោយកូនកូននឹងបានហូបហើយក៏មិនចង់បានហើយនឹងលក់ដូរអីដែលហាសចាសពីព្រោះអីនឹងយើង

ធ្លាប់អស់មានពីមុនមកហើយចឹងហាសចាសហើយនៅពេលដែលយើងបានមកបានមក ហើយចឹងហើយយើងបានត្រីច្រើនចឹងគឺយើងមិនបានខំប្រឹងនឹងលក់វានោះទេហើយយើង ខំប្រឹងទុក្ខវាដើម្បីអោយបានហូបទៅបានឆ្ងាញ់ហាសចាសនឹងហើយពីព្រោះអីនឹងយើងអ ស់មានពីមុនមកហើយចឹងហើយបានជាយើងនឹងខំប្រឹងទុក្ខវាចឹងទៅសំរាប់ទុក្ខហូបចឹងទៅ ចាស៕

ក៖
បាទហើយចឹងអរគុណាច្រើនអ្នកមីងហើយចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើសំរាប់បច្ចុប្ប ន្ននេះសំរាប់អ្នកមីងប្រកបមុខរបបអ្វីដែលទៅអ្នកមីងអាចប្រាប់ខ្ញុំបានដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនាពេលបច្ចុប្បន្ននេះគឺខ្ញុំប្រកបមុខរបបធ្វើចំការហើយនឹងលក់ដូចបន្តិចបន្តួច ចឹងទៅហាសចាសហើយនៅពេលដែលធ្វើចំការហើយនឹងប្តីរបស់ខ្ញុំនឹងគឺគាត់បានធ្វើចំការ ចឹងទៅគឺខ្ញុំនឹងបានយកទៅលក់ចឹងទៅចាសហើយនៅពេលដែលទៅលក់ចឹងទៅហើយ យើងបានទៅទិញពីផ្សារទៀតទៀតចឹងទៅបានហើយអោយបានគ្រាប់មុខអីចឹងទៅហាស និយាយទៅគឺអោយបាន៩រឺក៏បាន១០មុខចឹងទៅហាសចាសហើយសំរាប់រាល់ថ្ងៃនឹងគឺរស់ ដូចថាគឺនៅចំការរបស់ខ្ញុំនឹងមានតែពោតហើយនឹងចេកតែប៉ុននឹងហាសចាសហើយក៏មាន ល្ហុងអីចឹងទៅចាសហើយដល់ពេលខែចុះរបបអីចឹងគឺយើងមានលក់ត្រលាចអីចឹងទៅហើ យនឹងមានល្ពៅអីចឹងទៅនិយាយទៅគឺគ្រាប់មុខដែលដល់ពេលហើយខែដែលអត់មានអីចឹ ងទៅយើងនឹងទៅទិញមកពីគេយកមកលក់ចឹងហាសនឹងហើយចាស៕

ក៖ បាទហើយចឹងសំរាប់អ្នកមីងបានដាំបន្លែនឹងច្រើនមុខមែនដែលទេអ្នកមីង???

ខ៖
ចាសសំរាប់បានដាំបន្លែនឹងច្រើនមុខហាសហើយប្រសិនជាដល់ខែកក្តិតនឹងសំរាប់ខ្ញុំបាន ដាំគ្រាប់ចឹងទៅមានដូចចេកពងមាន់អីចឹងទៅហើយនឹងមានប៉ែប៉ោះហើយនឹងត្រលាចហើ យនឹងល្ពៅអីចឹងទៅនិយាយទៅគឺយើងចេះតែដាំទៅណាហើយយើងបានជួរដីរបស់គេខ្លះចឹ ងទៅហាសចាសហើយមិនមែនដីរបស់យើងណាហើយសំរាប់ដីដែលនៅខាងត្បូរនឹងគឺសុ ទ្ធតែជួររបស់គេទាំងអស់នឹងហាសចាសនិយាយទៅសុទ្ធតែដីរបស់អ្នកដែលនៅភ្នំពេញដែ លពូកគាត់នឹងបានមកទិញនឹងហាសចាសហើយសំរាប់ដីខាងក្រោយនឹងសុទ្ធតែរបស់គេនឹ ងហាសចាសហើយសំរាប់គេបានជួរអោយចឹងទៅគឺខ្ញុំចេះតែធ្វើចឹងទៅហើយសំរាប់កូនរប ស់ខ្ញុំនឹងគឺគេបានដាំចេកពងមាន់អីចឹងទៅចេះតែជួយគ្នាចឹងទៅហើយបានលុយចែកគ្នាបា នចាយចឹងទៅហាសចាសហើយប្រសិនជាយើងបានទិញគេទាំងអស់នឹងក៏យើងនឹងមិនជា សូវបានចំនេញដែលហាសចាសនឹងសំរាប់លូវនឹងហាសទាល់តែគេនឹងបានដាំពីផ្ទះរបស់គឺ នឹងបានខ្លះចឹងទៅ
បានចំនេញនឹងហើយសំរាប់ទីផ្សារហាសគឺខ្ញុំបានសួរគេនឹងមួយព្រឹកមួយព្រឹកនឹងគឺ ១០០០០៛ មួយព្រឹកនឹងដឹងតែ ១០០០០៛

ហើយសំរាប់របស់ដែលយើងបានលក់នៅសល់នឹងហើយយើងបានយកទៅដាក់ផ្ទះរបស់គេនឹង ១យប់នឹង ១០០០រ រីក៏ ២០០០រចឹងទៅហើយសំរាប់ទឹកនឹង ២០០រ ហើយនឹងមានថង់អីទៀតនឹងនោះចាសសំរាប់មួយថ្ងៃមួយថ្ងៃនឹងចំណាយនឹងគឺយើងនឹងចំណាយច្រើនខ្លាំងណាស់ចាសហើយសំរាប់ចំណូលនឹងបានតិចតែសំរាប់ចំណាយនឹងវាមានច្រើនណាស់ចាស៕

កៈ
បាទហើយចឹងអរគុណច្រើនអ្នកមីងហើយចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើប្រសិនជាប្រៀបធៀបពីជំនាន់ពោលពតហើយនឹងមកប្រៀបធៀបមកដល់ពេលបច្ចុប្បន្ននេះថាតើអ្នកមីងគិតថាខុសគ្នាយ៉ាងមិចដែលទៅអ្នកមីង???

ខៈ
ចាសនិយាយទៅប្រសិនជាប្រៀបធៀបពីជំនាន់មុខមកដល់បច្ចុប្បន្ននេះគឺវាមានភាពខុសគ្នាខ្លាំងណាស់ចាសខុសដោយសារអីគឺខុសដោយសារសំរាប់លូវនឹងគឺយើងមានសំបូរសប្បាយហូបហើយនឹងមានផ្ទះខ្លួនឯងហើយនឹងលុយកាក់នឹងយើងបានកាន់ខ្លួនឯងចាសសំរាប់ជំនាន់នឹងគឺយើងគ្មានអ្វីកាន់នោះទេចាសហើយប្រសិនជាគេបានអោយនឹងបានហូបយើងនឹងបានហូបចឹងទៅហើយប្រសិនជាគេមិនបានអោយយើងនឹងបានហូបយើងនឹងក៏មិនបានហូបចឹងទៅហាសចាសនឹងសំរាប់ជំនាន់នឹងហាសហើយប្រសិនជាគេបានអោយយើងនឹងបានហូបឆ្អែតនឹងក៏បានហូបបានឆ្អែតចឹងទៅហើយប្រសិនជាគេមិនបានអោយយើងនឹងបានហូបបានឆ្អែតនឹងគឺយើងនឹងហូបបបរាវចឹងទៅហាសចាសនឹងហើយ៕

កៈ បាទហើយចឹងបានន័យថាខុសឆ្ងាយណាស់មែនដែលទេអ្នកមីង???

ខៈ
ចាសគឺខុសគ្នាឆ្ងាយខ្លាំងណាស់ចាសពីព្រោះអីនឹងសំរាប់លូវនឹងគឺយើងមានម៉ូតូសំរាបជិះហាសហើយសំរាប់ជំនាន់នោះគឺយើងគ្មានអ្វីនឹងជិះនោះទេចាសនិយាយទៅគឺដើររហូតហើយដើរដល់ណាក៏យើងនឹងដើរដែលរួចហើយមិដល់លូវនឹងគឺអស់ជើងអស់ហើយចាសហើយនៅពេលដែលមកស្អុងស្រូវស្អុងអីនឹងគឺសុទ្ធតែដើរគ្មានអីជិះនោះទេហើយលូវនឹងសំរាប់អ្នកដែលអត់នឹងគឺមានម៉ូតូដែលហាសចាសហើយសំរាប់កងនឹងគឺគេមិនសូវជាជិះនោះទេចាសហេហេហេហេ៕

កៈ
បាទហើយចឹងខ្ញុំចង់អោយអ្នកមីងបានចែកចាយបទពិសោធន៍របស់បានដែលថានៅពេលដែលបច្ចុប្បន្ននឹងមានភាពសប្បាយរីករាយអ្វីខ្លះជាមួយនឹងក្រុមគ្រួសាររបស់អ្នកមីងនឹងហាសអ្នកមីងអាចប្រាប់ខ្ញុំបានដែលឬទេអ្នកមីងនឹងជាអ្វីដែលសប្បាយនៅក្នុងជីវិតរបស់អ្នកមីងហាសអ្នកមីងអាចប្រាប់ខ្ញុំបានដែលរឺទេ???

ខ៖

ចាសនិយាយទៅសំរាប់ក្រុមគ្រួសាររបស់ខ្ញុំនឹងគឺសប្បាយគឺថាខ្ញុំបានចែកដីហើយនឹងចែកអីនឹងអោយកូនរបស់ខ្ញុំនឹងហាសហើយគឺខ្ញុំសប្បាយចិត្តហើយនឹងបានគ្រាប់គ្នាហើយនឹងបានអោយកូនបានរស់នៅនឹងគឺសំរាប់ខ្ញុំនឹងបានសប្បាយចិត្តហើយចឹងហាសចាសនឹងហើយកុំអោយតែគ្មានអ្វីអោយកូននឹងបានរស់នៅនឹងគឺបានខ្ញុំនឹងវាពិបាក់វិញតាហាសចាសហើយសំរាប់លូវនឹងយើងមានលុយចាយហើយនឹងមានបាយសំរាប់ហូបហើយនឹងវាមានភាពស្រួលបិននឹងហើយគឺខ្ញុំគ្មានពិបាក់អ្វីទៀតទេអោយតែកូននឹងបានរស់នៅចឹងទៅសំរាប់ដីនឹងប្រសិនជាខ្ញុំនឹងលក់នឹង ១៥០,០០០$ (ដូល្លារ)
នឹងគឺគេនឹងយកភ្លែមហាសតែយើងនឹងលក់ទៅណាពីព្រោះអីនឹងសំរាប់កូនចៅរបស់យើងទាំងអស់គ្នានឹងនៅកន្លែងនឹងហាសគឺជាកោះនឹងតែម្តងហាសចាសហើយសំរាប់ដីលូវនឹងសំរាប់១ម៉ែត្រនឹងគឺ ១០,០០០$ និយាយទៅអោយតែថាលក់ហាសចាស។៕

ក៖

បាទហើយចឹងអ្វីដែលអ្នកមីងសប្បាយជាងគេគឺជាក្រុមគ្រួសាររបស់អ្នកមីងនឹងបានជុំគ្នាមែនដែលទេអ្នកមីង???

ខ៖

ចាសនឹងហើយសំរាប់អ្វីដែលខ្ញុំនឹងបានសប្បាយជាងគេនឹងគឺក្រុមគ្រួសាររបស់ខ្ញុំនឹងបានជុំគ្នាចាសហើយសំរាប់ពីមុននឹងគឺយើងបានបែកគ្នាពីព្រោះអីនឹងសំរាប់ជំនាន់ពោលពតនឹងគឺយើងទាំងអស់គ្នានឹងបានបែកគ្នាហើយនៅពេលដែលយើងបានបែកគ្នានឹងគឺយើងមិនអាចនៅជិតគ្នានឹងបាននោះទេចាសហើយនៅពេលដែលយើងបានបែកគ្នានឹងគឺថាម្តាយនៅដោយហើយនឹងឪពុកនៅដោយឪពុកចឹងហាសហើយសំរាប់បងប្អូននឹងក៏បានបែកគ្នាដែលហើយសំរាប់លូវនឹងគឺយើងទាំងអស់នឹងបាននៅជុំគ្នាទាំងអស់គ្នាវិញចាសទាំងចៅហើយនឹងទាំងកូនទាំងអស់តែម្តងចាសនិយាយទៅទោះមានហូបហើយនឹងអត់មានអីហូបនឹងក៏យើងនឹងបានសប្បាយចិត្តដែលពីព្រោះអីនឹងគឺយើងទាំងអស់គ្នានឹងបានរស់នៅជុំគ្នាទាំងចៅហើយនឹងទាំងកូនរបស់យើងទាំងអស់នឹងចាសហើយសំរាប់ជំនាន់ពោលពតនឹងមានបានរស់នៅជុំគ្នាណាគឺរស់នៅបែកគ្នាហាសចាសទាំងអស់នឹងហើយសំរាប់អ្នកខ្លះនឹងបានទៅហើយសំរាប់អ្នកខ្លះទៀតនឹងបានទៅនោះចឹងទៅចាស។៕

ក៖

បាទហើយចឹងសំរាប់ថ្ងៃនឹងខ្ញុំសប្បាយចិត្តមែនទែនអ្នកមីងដែលបានផ្តល់ប្រឹក្សាហើយនឹងបានផ្តល់យោលបល់ហើយជាពិសេសអ្នកមីងដែលបានផ្តល់ការប្រឹក្សាហើយនឹងពីជីវិតរបស់អ្នកមីងនៅក្នុងជំនាន់ពោលពតដែលមានភាពជីវិតលំបាក់ចឹងសំណួរចង់ក្រោយដែលខ្ញុំចង់សួរអ្នកមីងចង់ក្រោយថាតើអ្នកមីងមានអ្វីផ្តែលផ្តាំទៅកូនចៅរបស់អ្នកមីងដែលរឺទេនៅពេលដែលពួកគាត់បានលឺសំលេងហើយនឹងពេជ្ររបស់អ្នកមីងដែលនៅក្នុងសំលេងមួយនេះហើយសំរាប់អ្នកមីងចង់ផ្តែលផ្តាំអ្វីគេខ្លះទៅកាន់កូនរបស់អ្នកមីងដែលពួកគាត់បានលឺ

សំលេងមួយនេះដែលនៅក្នុង Website
របស់យើងមួយនេះថាតើអ្នកមីងមានអ្វីចង់និយាយដែលរឺទេអ្នកមីងដូចជាចង់អោយកូនចៅ
របស់អ្នកមីងធ្វើអំពើល្អដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំគឺខ្ញុំចង់ផ្ដែលផ្ដាំអោយសប្បាយចិត្តហើយនឹងធ្វើអ្វីអ្វីដែលល្អល្អកុំអោយមាន
ការលំបាក់កំបិនដូចនៅក្នុងជំនាន់ពោលពតទៀតហើយនឹងខំប្រឹងរកហើយនឹងខំធ្វើហើយ
នឹងធ្វើការងារបានលុយច្រើនច្រើននឹងហើយគឺខ្ញុំសប្បាយចិត្តហោហោហោហោសំរាប់ជំនាន់
ពោលពតចាសគឺកុំអោយដូចជំនាន់ពោលពតទៀតហាសចាសហើយអោយកូនចៅនឹងប្រឹ
ងរកហើយនឹងសល់សល់លុយកាក់នឹងហាសចាស៕

ក៖
បាទហើយចឹងអ្នកមីងមានអ្វីបន្ថែមទៀតដែលរឺទេដើម្បីអោយពួកគាត់ខំប្រឹងរៀនសូត្រអោ
យបានល្អអីចឹងហាសអ្នកមីងមានអ្វីនយាយទៀតទេអ្នកមីង???

ខ៖
ចាសហើយលូវនឹងគឺខ្ញុំសូមនិយាយទៅកាន់កូនកូនរបស់គឺនៅតែកូនពៅរបស់ខ្ញុំនឹងហើយ
សំរាប់អាវ៉ានឹងគឺវាបានឈប់រៀនហើយនៅតែមីពៅរបស់ខ្ញុំនឹងខ្ញុំសូមផ្ដាំផ្ញើរអោយវានឹងខំ
ប្រឹងរៀនសូត្រអោយបានធ្វើការងារនឹងហាសចាសគឺនៅសល់តែមីពៅនឹងសូមអោយវានឹង
ខំប្រឹងរៀនសូត្រដែលនៅសព្វថ្ងៃហាសចាសផ្ដាំអោយពួកវានឹងខំប្រឹងនឹងហាសហើយអោ
យបានរៀនសូត្រអោយបានចប់ហើយនឹងបានការងារធ្វើអីចឹងហាសចាសដូចថាបានប្រាប់
កូនរបស់ខ្ញុំនឹងរាល់ថ្ងៃនឹងហើយនឹងសំរាប់ចៅចៅអីនឹងគឺខំប្រឹងរៀនសូត្រអីចឹងទៅហើយនិ
យាយទៅគឺខ្ញុំគ្រាន់តែបានតែមួយផ្ដាំនោះទេហើយតិចទៀតទៅមុខទៀតទៅគឺខ្ញុំទៅផ្ដាំណា
កើតទៀតហោហោហោហោហោ៕

ក៖
បាទហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំអរគុណច្រើនមែនទែនអ្នកមីងដែលនិយាយជាមួយនឹងអ្នក
មីងហើយបានផ្ដល់យោបល់ហើយនឹងបានសប្បាយចិត្តបាទអរគុណច្រើនអ្នកមីង???

ខ៖
ចាសថ្ងៃនឹងខ្ញុំក៏សប្បាយចិត្តជាមួយនឹងក្មួយហើយបានសប្បាយចិត្តហើយនឹងបានជួយអ្នក
មីងបានឆ្លងទូតដរហើយខ្ញុំសូមផ្ដាំអាកូនហ្សៃនឹងមួយផងហាសកុំអោយពូកែផឹកពេកអោយ
ផ្អាក់ខ្លះទៅហាសចាសហើយអោយខំប្រឹងធ្វើការងារហើយរកស៊ីហើយនឹងខំប្រឹងធ្វើផ្ទះធ្វើ
សំបែងអីនឹងហាសចាស៕

ក៖ បាទហើយចឹងអ្នកមីងមានផ្ដែលផ្ដាំអ្វីទៀតដែលរឺទេអ្នកមីង???

ខ៖ ចាសនិយាយទៅគឺអស់ហើយហោហោហោចាស៕

ក៖
បាទហើយចឹងអ្នកមីងអស់ហើយមែនដែលទេអ្នកមីងហេហេហេហេហេហេចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំអរគុណច្រើនមែនទែនអ្នកមីងហើយចឹងថ្ងៃនឹងគឺខ្ញុំគ្មានទៀតនោះទេសំរាប់អ្នកមីងហើយខ្ញុំពិតជាសប្បាយចិត្តមែនទែនដែលបានអោយខ្ញុំបានជួបនឹងអ្នកមីងហើយបានសំភាសន៍អ្នកមីងជីវប្រវត្តរបស់អ្នកមីងដែលនៅក្នុងជំនាន់ពោលពតរហូតមកដល់បច្ចុប្បន្ននេះហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំសប្បាយចិត្តហើយខ្ញុំអរគុណច្រើនអ្នកមីងហើយសំរាប់ថ្ងៃនឹងគឺខ្ញុំអស់ហើយហើយខ្ញុំមានតែប៉ុននឹងអ្នកមីងហើយចឹងអរគុណច្រើនណាអ្នកមីងហើយចឹងខ្ញុំជំរាបលាណាអ្នកមីង៕